## វគ្គទី១៩

## កោះស្មៅលឿង

....ព្រះទិនករបាចសាចកាំរស្មីភ្លឺថ្លាប្រណាំងជាមួយកម្លាំងខ្យល់ត្រជាក់ស្រៀវឆ្អឹងខ្នងលើដែនកោះតូចមួយរបស់ខេត្តប៉ាពូ។ វាមិនចម្លែកទេដែលនារីទាំងឡាយនៅលើខេត្តនេះត្រូវស្លៀកពាក់ជិតជុំរុំដងខ្លួនពីលើដល់ក្រោមរួមទាំងសក់ក្បាលផង ដោយបញ្ចេញតែផ្ទៃមុខសខ្ចី និងភ្នែកទាំងគូខ្មៅក្រិបនិងធំៗដូចអារ៉ាប។

ដោយសារភាពស្រស់ស្អាតពីធម្មជាតិ និងសម្លៀកបំពាក់របស់ឌីម៉ាមានលក្ខណៈហាក់ហួសហេតុសម្រាប់ពលរដ្ឋនៅលើកោះ នាងត្រូវបានគេតាមសម្លឹងស្ទើរតែធ្លុះរាងកាយ នៅពេលនាងចុះពីកប៉ាល់ ប្រុងដើរចច្រប់ជាមួយរាមនរិន្ទបម្រុងចូលទៅកាន់ទីផ្សារក្បែរកំពង់ចម្លងJelly។ ដូច្នេះហើយការបកមកកាន់កប៉ាល់រកសម្លៀកបំពាក់សមរម្យ និងកន្សែងរុំក្បាលជាមធ្យោបាយល្អជាង។ តរុណីឌីម៉ាបកមកកាន់បន្ទប់សម្រាកក្នុងកប៉ាល់វិញដោយមាននាយគង់ជូនដំណើរ និងរង់ចាំការពារពីក្រៅផង។ នាងរើសព្វទាំងវ៉ាលិសសម្លៀកបំពាក់ហើយនៅតែមិនអាចរកបានសម្លៀកបំពាក់ណាដែលអាចប្រើឲ្យច្រទ្បំនឹងគេនៅតំបន់នេះឡើយ ម្ល៉ោះហើយទើបស្រីស្អាតត្រូវចេញទៅក្រៅប្រាប់អង្គរក្សគង់ឲ្យចេញទៅរកទិញនៅទីផ្សារឲ្យនាងនូវសម្លៀកបំពាក់របស់ស្រី! កោះស្មៅលឿង។

បុរសនោះទីទើរណាស់ទម្រាំដាច់ចិត្តចាកចេញពីកប៉ាល់ដោយសារគេញញើតពីសុវត្ថិភាពនាង។ តាមពិតកេតឌីម៉ាក៏មិនសូវស្រួលចិត្តនៅពេលមកដល់កោះនេះប៉ុន្មានដែរ ដោយសារលក្ខណៈប្រជាជនហាក់ខុសគ្នាទាំងស្រុងជាមួយស្រុកសាមី។ នៅកំពង់ផែសាមីហោចណាស់ក៏មានកូនតៀមភេសជ្ជៈដើម្បីឈប់សំចតយកកម្លាំងដែរតែនៅទីនេះមិនមានអ្វីទាំងអស់ក្រៅតែពីជម្រាលស្មៅលាតសន្ធឹងតាមបណ្ដោយដងទន្លេហើយមានទីប្រជុំជនតូចមួយដែលមានបុរសស្ត្រីប្រើសម្លៀកបំពាក់បុរាណតាមបែបសាសនាហើយពោរពេញទៅដោយទឹកមុខសោះអង្គើយចំពោះជនចំណូលថ្មីណាដែលមិនប្រើសម្លៀកបំពាក់បិទបាំងតាមប្រពៃណីរបស់ពួកគេ។

ស្រីបង្ហាញម៉ូតដឹងថា ប្រុសស្នេហ៍ និងអង្គរក្សរឿន ព្រមទាំងគ្នីគ្នាកំពុងចេញទៅស្វះស្វែងរកព័ត៌មានពីលោកវ៉ាទូ បុរសដែលអះអាងថាខ្លួនមានឥន្ទប្បដិមានរាធិបតិន្ទនៅឯពិធីដេញថ្លៃ Winter Jayapuraដែលទោះបីមិនចង់រំខានដល់ការងារគេ ក៏នារីតែចង់នៅរួមសុខទុក្ខក្បែរគេរាល់ថ្ងៃ ព្រោះថាពេលវេលាបែកគ្នាកាន់តែកៀកចូលមកដល់ហើយ។ តាមរយៈកិច្ចសន្យាស្នេហ៍លើទន្លេម៉េបីវ៉ាម៉ូនារីដឹងថា រយៈពេលបីឆ្នាំនៃការបែកគ្នាកំពុងឈានមកកាន់តែកៀក ដូច្នេះហើយតាមការទាមទារ

នៃបេះដូងនាងកាន់តែចង់ចំណាយពេលចុងក្រោយនៅក្បែររាមនរិន្ទ។ ដែលនាងចង់បានសម្លៀកបំពាក់ដូចនារីនៅកោះស្មៅលឿង គឺមកពីនាងចង់ចប្រប់ក្បែរគេគ្រប់ទិសទីនេះឯង។

ឱម៉ាអង្គុយសំកុកក្នុងបន្ទប់គេងរង់ចាំនាយគង់ទៅទិញសម្លៀកបំពាក់មក ប៉ុន្តែក្នុងបេះដូងនាងមានតែរូបរាង និងស្នាមញញឹមរបស់កូនប្រុសអ្នកនយោបាយ។ ពាក្យពេចន៍ស្នេហារបស់គេនៅលើដងទន្លេកាលពីរំលងអាធ្រាត្រនេះ លាន់រណ្តំក្នុងសោតាទាំងទ្វេ នឹកឃើញកាលណាក៏កាន់តែពិបាកចិត្តប៉ុន្តែហេតុអ្វីបានជានាងនៅតែចង់នឹកឃើញមិនចេះឈប់ឈរ។ សំឡេងស្រាលៗមួយលាន់មកពីក្រោយខ្នងស្រីបង្ហាញម៉ូតៈ

-ឱម៉ា!

ស្វាងចេញពីវិបត្តិស្នេហ៍ ស្រីស្អាតបើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើលៈ

-លំអង?

ឱម៉ាបែរក្រោយរឹងសម្លឹងទៅនារីជាមិត្តដែលមានវត្តមានតាំងពីពេលណាក៏មិនដឹង នៅក្នុងបន្ទប់ដែលមិនដែលមានអ្នកណាហ៊ានចូលមកក្រៅពីនាង និងនរិន្ទ។ នាងស្ទុះក្រោកដោយភិតភ័យព្រោះឃើញលំអងក្នុងសម្លៀកបំពាក់ខ្មៅពីលើដល់ក្រោម។ នារីដែលធ្លាប់តែស៊ីវិល័យ ពេលនេះឃ្លុំសំពត់ខ្មៅពីលើមុខរបស់នាងបញ្ចេញតែភ្នែកទាំងគូដូចនារីអារ៉ាបប្រកាន់វិន័យសាសនាតឹងរ៉ឹង។

ទោះបីមិត្តដែលធ្លាប់មានល្បិចព្រមដោះក្រណាត់ខ្មៅចេញបង្ហាញមុខឲ្យនាងស្គាល់ហើយ ក៏ឱម៉ានៅតែស្លេកស្លាំង។ ឆ្លងកាត់កលល្បិចច្រើនរាប់មិនអស់ចាប់តាំងពីនាងមានពាណិជ្ជកររដែកថែបក្នុងបេះដូងរហូតដល់ពេលនេះ នាងនៅសល់តែរាមនរិន្ទក្នុងប្រអប់ទ្រូង នាងចាប់ផ្តើមចេះប្រយ័ត្នខ្លួន និងវាងវៃជាងមុន។ ភាពទៀងត្រង់របស់ធីតាបង្ហាញម៉ូតដែលត្រូវភាពទ្រុស្តរបស់មិត្តវាយឲ្យស្រងល់នោះ បានបង្កើតចេញនូវភាពភ័យខ្លាចមួយឲ្យនាង នៅពេលដែលនាងចាប់ផ្តើមជួបលំអងសាជាថ្មីនៅពេលដ៏ប្រចុចញ៉ុចនេះ។ ភ្លាមៗនោះឱម៉ាឃើញលំអង គឺនាងហាក់បានឃើញមុខបុរសបោកប្រាស់ឈ្មោះ Kenនោះដែរ។ ពិសេសពេលនេះជីវិតនាងគឺសម្រាប់តែកូនប្រុសអ្នកនយោបាយទៅហើយ អ្នកដែលជាសត្រូវរបស់រាមនរិន្ទគឺនាងចាត់ថាជាសត្រូវរបស់នាងដែរ។ ដូច្នេះហើយរូបរាងលំអងពេលនេះ គឺជាស្រមោលអពមង្គលសម្រាប់នាង។ ឱម៉ាស្រែកតិចៗដោយភិតភ័យៈ

-ម៉េចក៏ឯងចូលមកបាន?

លំអងដែលប្រឡាក់ប្រឡូសមុខមាត់ក្រវេមក្រវាមហាក់ដូចទើបរត់គេចចេញពីរឿងអ្វីមួយ ប្រឹងនិយាយមកកាន់មិត្តនារីស្លូតត្រង់របស់ខ្លួនដោយរលីងរលោងទឹកភ្នែក៖

-ឌីម៉ា! ឯងជួយខ្ញុំផង! ខ្ញុំត្រូវការឲ្យឯងជួយ! គ្នាត្រូវការត្រឡប់ទៅស្រុកខ្មែរវិញ! ជួយគ្នាផង! គ្នាមានតែឯងម្នាក់ទេដែលអាចជួយគ្នាបាន!

ទឹកភ្នែក និងសព្ទរអាក់រអួលរបស់មិត្ត ធ្វើឲ្យនារីតួឯកនឹកឃើញដល់ឆាកល្ខោននៅរាត្រីចុងក្រោយនាកោះបាលីដែលលំអងបានយំយែកបោកបញ្ឆោតឲ្យខ្លួនត្រូវចូលទៅរកវាមនរិន្ទទាំងអាធ្រាត្រ។ ក្រោយមកនាងទើបតែដឹងថាគេបានធ្វើរឿងជាច្រើនព្រោះតែគេជាសង្សារលួចលាក់របស់Ken ហើយគេចង់បានព័ត៌មានពីវាមនរិន្ទប្រាប់ទៅសង្សារគេ ចំណែកឯមិត្តភាពទាំងឡាយដែលនាងមានឲ្យគេដោយស្មោះ គឺគេបានគ្រវែងវាចោលក្នុងទន្លេក្បត់ទៅហើយ។

នាងនិយាយតបដោយងាកមុខទៅម្ខាង ហើយមិនខ្វីសម្លឹងមុខស្រីដែលធ្លាប់ធ្វើឲ្យនាងឈឺចាប់៖

-ក្រែងឯង និងប្រុសនោះបានសម្រេចដូចបំណងហើយហ្អី? ឯងនាំគ្នាប្រជែងជាមួយលោកប្រុសរាមបានសម្រេច ហើយបានមកដល់កន្លែងនេះមុនពួកខ្ញុំមកដល់ទៀត ឯងចង់ត្រលប់ទៅភ្នំពេញវិញម៉េចមិនរកប្រុសនោះឲ្យគេជូនឯងទៅ?

លំអងក្នុងសម្លៀកបំពាក់ខ្មៅ ស្ទុះមកឱបមិត្ត តែត្រូវនាងគេចចេញ។ នារីលង់ខ្លួន ដឹងថាកេតឌីម៉ាលែងទុកនាងជាមិត្តដូចមុនហើយ នាងកាន់តែយំសស្រាក់ និយាយអង្វរស្រីស្អាតដែលឈរបែរខ្នងដោយទឹកមុខឈឺចាប់៖

-ឌីម៉ា! គ្នាដឹងថានិយាយយ៉ាងណាក៏ឯងលែងជឿគ្នាហើយដែរ! តែយល់ថាយើងស្គាល់គ្នា សូមឯងជួយខ្ញុំម្តងទៀតជាចុងក្រោយទៀតចុះ! បើមិនអញ្ចឹងទេ គ្នាច្បាស់ជាស្លាប់ចោលឆ្អឹងនៅទីនេះហើយ!

គ្នាមិនចង់ស្លាប់នៅស្រុកគេទេឌីម៉ា! គ្នាសូមអង្វរឯង!

ឌីម៉ាដែលតាំងចិត្តថានឹងមិនព្រមលុះក្រោមកលល្បិចរបស់មនុស្សក្បត់មិត្តជាលើកទី២ទៀតទេនោះ គិតថានឹងដេញនាងចេញពីទីនេះដើម្បីជៀសវាងនឹងការទន់ចិត្តចំពោះទុក្ខសោកក្លែងក្លាយរបស់ពួកគេជាថ្មីទៀត ប៉ុន្តែភ្លាមនោះនាងស្រាប់តែនឹកឃើញចម្លែកក្នុងចិត្ត។

នាងបែរក្រោយសម្លឹងស្ថានភាពរបស់នារីស៊ីវិល័យដែលធ្លាប់តែតែងខ្លួនហ៊ឺហាឡូយឆាយ ម្តេចក៏ពេលនេះ នាងប្រើសម្លៀកបំពាក់អារ៉ាប Hijab បិទបាំងអត្តសញ្ញាណដូចជាកំពុងគេចវេះពីអ្នកណា

ម្នាក់? ឬមួយនាងធ្វើយ៉ាងនេះដើម្បីគេចវេះពីកូនចៅរាមនរិន្ទ ហើយឡើងមកក្នុងគោលបំណង បោកប្រាស់នាងដោយឧបាយកលអ្វីមួយថ្មីទៀត?

នាងនិយាយដោយប្រឹងពង្រឹងស្មារតី និងកាត់ចិត្តធ្វើជាចិត្តរឹង៖

-លំអង! ឯងឆាប់ចេញទៅវិញទៅ មុនពេលលោកប្រុសរាម ឬក៏អង្គរក្សរឿនមកដល់!

ពួកគេប្រាកដជាខឹងពេលឃើញឯង! ពិសេសអង្គរក្សនោះ ឯងដឹងចរិតគេហើយ!

ប៉ុន្តែសម្ដីរបស់ឌីម៉ា មិនត្រឹមតែមិនអាចបន្លាចលំអង ថែមទាំងត្រូវលំអងតបតមកវិញ៖

-ទោះយ៉ាងណាក៏ពួកគេជាខ្មែរដូចគ្នា! ខ្ញុំមិនខ្លាចខ្មែរដូចគ្នាទេ! បើស្លាប់ដោយសារខ្មែរដូចគ្នា វាគ្រាន់ជាងឲ្យពួកកុលសម្ព័ន្ធសម្លាប់ដែរ!

ពាក្យកុលសម្ព័ន្ធដែលនាងទើបតែបង្ហើបមានឥទ្ធិពលឲ្យបេះដូងមាណវីស្លូតត្រង់ដែលកំពុងស្ដាប់ទៅជាលោតញាប់។ នាងស្រាប់តែនឹកឃើញភ្លាមដល់អន្ទាក់គ្រោះថ្នាក់នៅភូមិភូរីខាន់ដែលទើបតែកន្លងរួចថ្មីៗ។ តាពុកចង្កាឈ្មោះអូណ៉ារ គេមិនត្រឹមតែចង់បាននាងទេ តែថែមទាំងបើកដៃឲ្យសិទ្ធិគុណអាចចូលមកធ្វើបាបរាមនរិន្ទបានតាមចិត្តផង។ ទម្រាំតែឆ្លងផុតឧបសគ្គនោះបាននាងនឹងរាមនរិន្ទសឹងក្លាយជាអ្នករងគ្រោះទាំងគ្មានកំហុសបាត់ទៅហើយ ចុះតើកុលសម្ព័ន្ធដែលលំអងកំពុងលើកឡើងនេះ តើជាអ្នកណាទៀត?

ព្រោះសុវត្ថិភាពរបស់បុរសកំពូលស្នេហ៍ គឺជាអាទិភាពនាងងាកមកសួរលំអងដើម្បីបញ្ជាក់៖

-កុលសម្ព័ន្ធអីទៅ? ក្រែងពួកឯងមករកលោកវ៉ាទូដើម្បីរបស់នោះមែនទេ?

លំអងអរណាស់ដែលឌីម៉ានៅជជីកសួរចុះឡើង មានន័យថានាងនៅព្រមស្ដាប់ នាងនិយាយបន្តភ្លាមទាន់ឱកាសហុចឲ្យ៖

-លោកវ៉ាទូនោះជាមនុស្សបោកប្រាស់ទេ! Kenត្រូវវាចាប់បាត់ហើយ! មិនដឹងយ៉ាងណាយ៉ាងណីហើយទេ!

និមិត្តតែឮឈ្មោះបុរសនោះ នាងចាប់ក្ដៅចិត្តភ្លាម។ ទង្វើបញ្ឆោតបោកប្រើមនុស្សស្រីដ៏កំសាករបស់នាយនោះ មិនត្រឹមតែបំផ្លាញទាំងស្រុងនូវមនោសញ្ចេតនារបស់នាងកាលពីមុនមកនោះទេ ថែមទាំងធ្វើឲ្យនាងនឹកចង់ឲ្យនាយនោះរងបាបកម្មទៀតផង ដើម្បីតបសងនូវកំហុសដែលនាងបានជ្រុលជាធ្វើឲ្យរាមនរិន្ទខូចការធំ។ ឌីម៉ាសើចចំអកដោយឈឺចាប់៖

-ក្រែងពីរនាក់ឯងឆ្លាតណាស់ហ្អី? សម្បូរល្បិចណាស់ហ្អី? ហេតុអីក៏ធ្លាក់ខ្លួនដល់ម្លឹងៗ?

នាងបែរខ្លួនចាកចេញដោយមុខក្រហម ប៉ុន្តែសំឡេងលំអងលាន់មកពីក្រោយខ្នង៖

-សូម្បីតែលោកប្រុសរាមក៏នឹងជួបទុក្ខដែរ បើនៅតែទៅជួបអារ៉ាទូនោះ! ពិសេសឯងហ្នឹងក៏អញ្ចឹង វានោះឃើញស្រីមិនបានទេ ព្រោះវាមិនដែលបានឃើញស្រីស្អាតនៅកន្លែងវា!

ឪម៉ាចងចិញ្ចើម នាងរវេរវ៉ាក្នុងពេលដែលក្បាលវិលខ្វាល់ជុំវិញចំណោទថ្មីនេះ។

ដោយប្រការណាក៏ដោយ នាងត្រូវតែការពារបុរសដែលនាងមានគេពេញក្នុងបេះដូង ដូច្នេះហើយបានជានាងងាកក្រោយសួរនារីអាវខ្មៅយ៉ាងរហ័ស៖

-ឯងថាម៉េច? លោកវ៉ាទូហ្នឹងអ្វី?

លំអងនិយាយតបវិញបន្តបន្ទាន់៖

-ឪម៉ា! ម្សិលមិញពួកខ្ញុំមកជិតដល់កោះនេះ យើងជួបព្យុះមួយ ទម្រាំខ្យល់ស្ងប់នៅលើទូកសល់តែគ្នា បងKen និងអ្នកបើកទេ! យើងត្រដាបត្រដួសទៅរកតាមវ៉ាទូហ្នឹងដល់ភូមិវាទាំងព្រលប់ វាថាឲ្យយើងចូលសម្រាកសិន នឹងអាលយករបស់មកនិយាយលក់ដូរ ប៉ុន្តែដឹងអីគឺវាដាក់ថ្នាំក្នុងស្រាឲ្យយើងផឹក!ខ្ញុំសំណាងមិនបានផឹករបស់ហ្នឹង បានជាកណ្តាលយប់ខ្ញុំលួចចេញមកបាន! គ្នារត់តាមជើងភ្នំពិបាកណាស់ ទម្រាំបានមកដល់កំពង់ចម្លងនេះហើយឡើងមករកឯង! គ្នាមកនេះគឺមកអង្វរឯង ប្រុសនោះគេស្តាប់ឯងណាស់ គេក៏មានកម្លាំងច្រើន ឯងឲ្យគេជួយគ្នាផង ឲ្យគ្នាបានវិលទៅស្រុកខ្មែរវិញ! គ្នាមិនភ្លេចគុណឯងទេ! គ្នាសូមអង្វរឪម៉ា!

ឪម៉ាចាប់ផ្តើមហួសចិត្ត នាងនឹកឃើញថាទោះយ៉ាងណាក៏លំអង និងនាយពាណិជ្ជករឈោមត្រជាក់នោះបានឆ្លងកាត់នូវផែនការអាក្រក់មកជាមួយគ្នាជាច្រើនហេតុ ដល់ពេលមានវិបត្តិគេបែរជារត់ចោលគ្នាបានដូចគ្មានមនោសញ្ចេតនាអញ្ចឹងទៅកើត?។ បើម្នាក់កំពុងជួបទុក្ខចុះម៉េចក៏ម្នាក់ទៀតសុខចិត្តរត់ទៅស្រុកខ្មែរវិញមុន? ទោះបីអតីតកាលអាក្រក់របស់លំអងបានបង្អាក់មិនឲ្យឪម៉ាព្រមជឿសម្តីនាងងាយៗ ប៉ុន្តែនឹកដល់រាមនរិន្ទពេលណានាងកាន់តែមានពិភាល់ក្នុងចិត្ត។ ចុះបើសម្តីលំអងជាការពិតវិញ តើបុរសកូនអ្នកនយោបាយមានវិធីណាដើម្បីដោះខ្លួនបាន បើពេលនេះគេកំពុងជាន់ដីថ្មីមួយដែលស្ថិតក្នុងកណ្តាប់ដៃពួកនោះទៅហើយ?

នាងនិយាយតបទៅលំអង៖

-តាវ៉ាទូធ្វើអញ្ចឹងដើម្បីអ្វី?

លំអងបង្ហាញភាពស្មុគស្មាញលើផ្ទៃមុខ នាងនិយាយតប៖

-គ្នាក៏អត់ដឹងដែរ! ប៉ុន្តែ...ប៉ុន្តែទាំងលោកប្រុសរាម..ទាំងKenសុទ្ធតែជាអ្នកមាន បើពួកនោះចាប់បានក្នុងដៃ វាមិនដែលអត់ប្រយោជន៍វាទេ! សរុបទៅរឿងដេញថ្លៃ រឿងអីហ្នឹងសុទ្ធជារឿងបោកប្រាស់! ខ្ញុំយល់ថាវាគ្មានរបស់នោះទេ តែវាប្រឌិតរឿងហើយធ្វើជាដាក់គ្រាប់បែកនៅ JayaPura ដើម្បីឲ្យម្នាក់ៗមកតាមដល់នេះ! វាអាចមានគម្រោងការចាប់មនុស្សជំរិតទារលុយក៏ថាបាន!

ឱម៉ាបើកភ្នែកធំៗ។ នាងនឹកឃើញភ្លាមដល់សម្ដីរាមនរិន្ទនៅភូមិភូរីខាន់ដែលបាននិយាយប្រាប់ឱពុកមានាយសិទ្ធិគុណ ថាពួកតាមអួណ័រមានពាក់ព័ន្ធដល់ការដាក់គ្រាប់បែក នៅសណ្ឋាគារ Winter JayaPuraប៉ុន្តែតើក្រុមនោះមានទាក់ទងអ្វីជាមួយនឹងលោកវ៉ាទូ? ប្រមុខកន្នីរីហ្វេសស្សិនបន្លឺសំនួរភ្លាម៖

-ម៉េចក៏ឯងច្បាស់ម៉េះ?

លំអងឈានចូលមកក្បែរមិត្ត នាងនិយាយបន្ថែមដោយទឹកមុខអង្វរករឲ្យគេជឿសម្ដីខ្លួន៖

-គ្នាមកនេះគ្មានចង់បានអីពីឯងទេ គ្នាគ្រាន់តែចង់ត្រឡប់ទៅវិញ ព្រោះគ្នាអត់មានអីជាប់ខ្លួនទាំងអស់! ដូចឯងដឹងហើយ សេដ្ឋី Kenជាមនុស្សអាក្រក់ គេមិនដែលមានចិត្តស្មោះទេ គ្នាមានអីត្រូវសង្ឃឹមនៅកន្លែងនេះទៀត? ដោយសារគេបានជាគ្នាខំកាត់មកដល់កន្លែងឆ្ងួតអស់នេះ ទីបំផុតដើម្បីរបស់នោះគេឲ្យគ្នាទៅដេកជាមួយពួកកុលសម្ព័ន្ធ ឯងគិតមើលទៅគ្នាមានរឿងអីត្រូវស្មោះជាមួយប្រុសធុនហ្នឹង? ឱម៉ា គ្នាពិបាកណាស់ទម្រាំចេញមកបាន គ្នាមិនចង់ធ្លាក់ក្នុងដៃពួកហ្នឹងទៀតទេ! ឯងព្រមជួយគ្នាជាចុងក្រោយទៅ គ្នាសូមអង្វរ!

ឱម៉ាកាន់តែពិបាកចិត្តនៅពេលឮថាពួកកុលសម្ព័ន្ធនៅទីនេះ ក៏ចង់បានស្រីស្អាតដូចនៅស្រុកសាមី។ដូច្នេះនាងដឹងថាហេតុការណ៍ចាស់ មុខជាកើតឡើងមកវិញមិនខាន។ នាងនិយាយខ្សោយៗដោយអស់កម្លាំងចិត្ត៖

-បើដូចឯងនិយាយមែន ពួកយើងទាំងអស់កំពុងស្ថិតក្នុងគ្រោះថ្នាក់ដូចគ្នា តើខ្ញុំមានអីជួយឯងបានទៅលំអង?

លំអងរត់មកតោងដៃមិត្ត៖

-ឱម៉ា! អ៊ីចេះទៅ! យើងពីរនាក់ទៅស្រុកខ្មែរវិញជាមួយគ្នា! ពួកប្រុសអ្នកមានអស់ហ្នឹង បើគេឆ្កួតនឹងរបស់បុរាណហ្នឹង ឲ្យគេធ្វើតាមចិត្តទៅ! យើងទៅវិញ! ម៉ោង៩នេះមានទូកគេចេញទៅ Jayapura ឯងយកលុយខ្លះមក! គ្នាគ្មានអីទាំងអស់ បានជាគ្នាទៅណាមិនបាន! ណ៎ាឱម៉ា ទៅដល់ Jayapura យើងឡើងយន្តហោះទៅស្រុកខ្មែរវិញ! ទៅដល់ថ្លៃសោហ៊ុយទាំងអស់យើងសងឯងវិញណ៎ា! ណ៎ាសម្លាញ់!

ឱម៉ានៅស្ងៀម ប៉ុន្តែអ្នកដែលនាងកំពុងគិតដល់គឺរាមនរិន្ទ។ សកម្មភាពដ៏ភិតភ័យសឹងមិនអាចគ្រប់គ្រងខ្លួនបានរបស់លំអង កាន់តែធ្វើឲ្យនាងសង្ស័យពីសុវត្ថិភាពប្រុសស្នេហ៍នៅលើដែនកោះដ៏អាថ៌កំបាំងនេះ។

ឃើញនាងនៅទ្រឹង លំអងតឿនបន្ថែម៖

-ឱម៉ា! កុំគិតយូរពេក! នេះមិនមែនជាប្រទេសរបស់យើងទេ! គ្មានបានការអីដែលត្រូវនៅកន្លែងឆ្កួតៗអស់ហ្នឹងទេ! ហើយប្រុសៗអស់ហ្នឹងក៏គេមិនមែនស្មោះស្ម័គ្រការពារយើងគ្រប់ពេលដែរ! គឺឲ្យតម្លៃតែរបស់បុរាណនោះ! កោតតែយើងខំស្មោះនឹងគេ! ទាន់រាមនរិន្ទមិនទាន់មកវិញ យើងនាំគ្នាចេញពីកន្លែងនេះទៅ!

ឱម៉ាដកដៃចេញពីមិត្តយឺតៗ។ នាងថយទៅម្ខាងហើយនិយាយមួយៗក្រោមពន្លឺភ្នែកសង្ស័យរបស់លំអង៖

-ខ្ញុំមិនទៅណាចោលគេទេ!

លំអងដៀងភ្នែករិះគិត៖

"កេតឱម៉ាស្រលាញ់លោកប្រុសរាមទៅហើយ? រយៈពេលខ្លីប៉ុណ្ណឹង ពីរនាក់គេយល់ចិត្តគ្នាទៅហើយហ្អី? ទោះបីយ៉ាងណាគេគ្រាន់បើជាងយើងដែលមានប្រុសល្អម្នាក់នៅក្បែរខ្លួនលើទឹកដីដ៏គ្រោះថ្នាក់នេះ។"

ស្រីឆ្លាតវៃដឹងថា ទោះនិយាយយ៉ាងណាក៏មិនអាចបំបែកនារីល្ងង់ខ្លៅចេញពីបុរសដែលនាងដាក់ចិត្តដាក់កាយថាស្រលាញ់នោះដែរ ពិសេសក្នុងកាលៈទេសៈដ៏គ្រោះថ្នាក់នេះ គឺរឹតតែអត់ទៅទៀត។នាងដកដង្ហើមធំ ងក់ក្បាលផ្ងក់ៗ៖

-បាន! ឯងនៅរួមសុខទុក្ខជាមួយគេក៏តាមចិត្ត! តែឯងត្រូវជួយគ្នា! ឯងឲ្យគ្នាខ្ចីលុយទិញសំបុត្រយន្តហោះមកណ៎ាឱម៉ា! គ្នាគ្មានអីទាំងអស់ដោយសារទុកចិត្តអ្នកមានចិត្តមារនោះពេក!

ឱម៉ាដកដង្ហើមធំវិញ។ នាងស្ទុះទៅរើកាបូបប្រាក់នៅចុងដំណេក ហុចដកប្រាក់ទាំងប៉ុន្មានចេញមកឲ្យលំអង៖

-ខ្ញុំមានតែប៉ុណ្ណឹងទេ! ឯងអាចទៅដល់ចាយ៉ាពូរ៉ាហើយCallទៅផ្ទះឲ្យគេផ្ញើមក! លុយនេះទិញសំបុត្រយន្តហោះអត់បានទេ!

លំអងនិយាយតបភ្លាមដោយតានតឹងចិត្ត៖

-Jayapuraក៏គ្មានសុវត្ថិភាពដែរ! ឯងនឹកឃើញរឿងគ្រាប់បែកហ្នឹងអត់? ពួកកុលសម្ព័ន្ធវាយមនុស្សពេញពាសហ្នឹង! ឱម៉ាឯងនៅជាមួយលោកប្រុសរាម មិនដែលថាគ្រាន់តែសំបុត្រយន្តហោះមួយ ឯងជួយគ្នាមិនបានសម្លាញ់? ឯងយកលុយរបស់គេឲ្យគ្នាខ្ចីសិនទៅ!

ឱម៉ាគ្រវីក្បាល៖

-ខ្ញុំគ្មានសិទ្ធិអីធ្វើអញ្ចឹងទេលំអង! ឯងយកលុយគ្នានេះហើយ ឆាប់ទៅៗ បើពួកគេមកវិញ គេនាំគ្នាធ្វើអីឯង គ្នាមិនដឹងធ្វើម៉េចទេ!

នាងដើរចេញទៅដើម្បីគេចចេញពីការជជីកអង្វររបស់លំអង តែនារីនោះចាប់ដៃឱម៉ាជាប់ជាមួយសូរសៀងរអាក់រអួល៖

-ឱម៉ា! គ្នារត់ចេញមក ឯងស្មានថាពួកហ្នឹងព្រមឲ្យគ្នាទៅបានស្រួលហ្អី? ឯងមិនត្រឹមតែមិនជួយគ្នាសូម្បីលុយក៏មិនព្រមឲ្យខ្ចី! ឯងជាមនុស្សរបស់គេ មានរឿងអីឯងគ្មានសិទ្ធិលើលុយកាក់តិចតួចប៉ុណ្ណឹង ឯងចាំដល់គេសម្លាប់គ្នាបំបិទមាត់បាត់ ចាំឯងមកស្រក់ទឹកភ្នែកស្តាយមែនទេ? លុយប៉ុណ្ណឹងអត់ច្រើនសម្រាប់គេទេ! ឯងមិននិយាយក៏គេមិនដឹងដែរ! ជួយគ្នាផងណ៎ា គ្នាមានតែឯងទៀតប៉ុណ្ណោះឱម៉ា!

ភាគទី៤២

កេតឱម៉ាសម្លឹងសោទូលើក្បាលគ្រែ។ នាងដឹងថារាមនរិន្ទមានប្រាក់ឥណ្ឌូណេស៊ីមួយចំនួននៅទីនោះ ដែលគេទុកសម្រាប់ឲ្យនាងប្រើប្រាស់តាមផ្លូវ។ ប្រាក់នោះយ៉ាងហោចណាស់ក៏ទិញសំបុត្របាន៥សន្លឹកដែរ កុំថាឡើយត្រឹមលំអងមួយ ប៉ុន្តែទោះក្តុកក្តួលអាណិតមិត្តប៉ុណ្ណា នាងនៅតែមិនដាច់ចិត្តប្រើប្រាស់សម្បត្តិបុរសនោះដោយគ្មានការអនុញ្ញាតដែរ។

នារីបង្ហាញម៉ូតឈ្មោកសម្លឹងខ្សែកតូចឆ្មារអមដោយបន្ដោងពេជ្រភ្លឺរន្ទាលលើផែនទ្រូង។ វាជាវត្ថុចុងក្រោយដែលនាងបានសេសសល់ពីអ្នកមានគុណ។ នាងលូកដៃដោះវាចេញ ហើយហុចទៅឲ្យមិត្តទាំងមិនសម្លឹងមុខនាងទេ។ អ្នកចិត្តសប្បុរសនិយាយមួយៗទៅរកលំអង៖

-មិនមែនខ្ញុំជួយឯងព្រោះអភ័យទោសឲ្យហើយទុកឯងជាមិត្តទេ! ក្នុងចិត្តយើង ឯងនិងប្រុសនោះបានស្លាប់បាត់ហើយ! យើងឲ្យរបស់នេះទៅឯង ព្រោះឯងជាខ្មែរម្នាក់ដែលរសាត់អណ្ដែតមកឆ្ងាយស្រុកដូចយើងដែរ! ពីមុនឯងធ្លាប់ជួយខ្ញុំម្ដង ពេលប្អូនខ្ញុំឈឺ ឯងនាំខ្ញុំទៅស្គាល់មីងកុលាប ទោះបីម្នាក់ៗសុទ្ធតែប្រើប្រាស់ខ្ញុំ តែក៏ដោយសារឯង និងគាត់ បានជាខ្ញុំបានជួបរាមនរិន្ទ! ថ្ងៃក្រោយយើងអត់មានអីទាក់ទាមជំពាក់គ្នាទៀតទេ! ហើយតទៅក៏មិនបាច់ស្គាល់គ្នាទៀតដែរ! ឯងចេញទៅចុះ កុំត្រឡប់មកវិញទៀត!

លំអងស្រក់ទឹកភ្នែក នាងនិយាយមួយៗ៖

-ឱម៉ា! នេះជាខ្សែកម្ដាយឯង ឯងកុំល្ងង់ពេក! ឯងនៅជាមួយគេ ឯងមានសិទ្ធិចាយលុយរបស់គេ ឯងមិនបាច់ចិត្តច្រើន មិនបាច់ក្រែងចិត្តគេទេ ឯងឈប់ល្ងង់ទៅ!

ឱម៉ារលីងរលោង នាងងាកមុខចេញ៖

-យើងជំពាក់គេច្រើនណាស់ហើយ! ប្រសិនបើគេជាមនុស្សដែលយើងស្រលាញ់ យើងរឹតតែមិនចង់ធ្វើខុស រឹតតែមិនចង់ជំពាក់អីគេទៀត! មានតែមនុស្សឆ្លាតដែលគ្មានបេះដូងដូចជាពួកឯងទេ ដែលធ្វើអញ្ចឹងកើត!

ស្គាល់កេតឱម៉ាយូរហើយ លំអងក៏ដឹងដែរថា ស្រីនេះត្បិតតែល្ងង់ហើយស្លូតត្រង់ ប៉ុន្តែក៏មានចិត្តមានះខ្លាំងណាស់។ បើនាងថាទេហើយ មិនមានអ្នកណាអាចផ្លាស់ប្ដូរចិត្តនាងបានទេ។

លំអងងើបមុខសម្លឹងទ្រនិចនាឡិកា នាងបែរខ្លួនដើរចេញយឺតៗដោយលែងចេញស្ដី។

ឱម៉ាលួចសម្លឹងតាមកញ្ចក់ពីក្រោយវាំងនន រហូតដល់រូបរាងលំអងបាំងបាត់ពីក្រោយជម្រាលស្មៅទើបនាងដកដង្ហើមយូរធូរចិត្តមកវិញ។ នាងនិយាយម្នាក់ឯង៖

-សូមឲ្យឯងបានសុខលំអង!

------------------------------------

នៅឯណោះវិញ រាមនរិន្ទអមដំណើរដោយអង្គរក្សរឿន និងដើរតាមពីក្រោយដោយក្រុមការពារ នាំគ្នាដើរយឺតៗ ហាក់បង្អូសដំណើររង់ចាំស្រីស្រស់ដែលត្រឡប់ទៅប្តូរសម្លៀកបំពាក់។

ទីប្រជុំជននៅកំពង់ជ Jelly គ្របដណ្តប់ដោយក្លិនប្រេងឈូករតន៍ និងលំអស្រស់បំព្រងដោយផ្កាជាច្រើនជំពូក ចោលក្លិនក្រអូបឈ្ងុយឈ្ងប់ ដែលត្រូវបានដឹកតាមសត្វលាមកតាំងលក់ត្រៀបត្រា។ ប្រពៃណីរស់នៅរបស់មនុស្សកោះស្មៅលឿងកាន់តែខុសប្លែកគ្នាជាមួយពលរដ្ឋដ៏ស៊ីវិល័យនៅក្រុងទេសចរបាលី ព្រមទាំងនៅធានី JayaPura។

នាយរឿនដើរបណ្តើរ មើលផែនទីក្នុងទូរសព្ទបណ្តើរ។ គេឈ្ងោកទៅជិតនាយថៅហ្វាយ ហើយពោលដោយឱនលំទោន៖

-អ្នកប្រុស! ចេញពីផ្សារយើងត្រូវធ្វើដំណើរកាត់តាមផ្លូវលំនេះ ហើយសសៀរតាមចង្កេះភ្នំប្រហែល ២គីឡូម៉ែត្របានទៅដល់មាត់បឹង។ ភូមិដែលលោករ៉ាទូប្រាប់ជាភូមិដែលប្រមូលផ្តុំសម្រាប់ពួកម្ចាស់ដី និងអម្បូរអ្នកគ្រប់គ្រងកុលសម្ព័ន្ធដែលមានឋានៈមានដី និងសត្វច្រើនជាងគេ។ ឆ្លងទឹកទៅយើងត្រូវឆ្លងវាលស្មៅនេះទៀតរហូតដល់ជ្រលងភ្នំទី២ នៅកន្លែងនោះមានភូមិបីបួនជិតៗគ្នា! យើងអាចទៅដល់ទីនោះ សួរគេរកលោករ៉ាទូបាន។ ឈ្មោះពេញរបស់គាត់ គឺរ៉ាទូ អាម៉ាដខាន់។

អង្គរក្សខ្ពស់ស្រាវងើបមុខសម្លឹងជុំវិញខ្លួនហើយទើបនិយាយបន្ត៖

-ផ្លូវទៅកន្លែងហ្នឹងពិបាកជិះឡានទៅណាស់ ហើយក៏គ្មានឡានល្អស្រួលជិះសម្រាប់ជួលដែរទាន! ខ្ញុំចង់សុំយោបល់អ្នកប្រុសរឿងរទេះសេះវិញ!

រាមនរិន្ទងាកក្រោយជារឿយៗ ព្រោះគេរង់ចាំដំណើរស្រីស្អាតរបស់គេ។ បបូរមាត់នាយពោលតបទៅកាន់នាយអង្គរក្ស៖

-ខ្ញុំអត់បញ្ហាទេរឿន! គិតតែរឿងស្រីៗទៅ គ្នាមិនសូវធន់លំបាកបានទេ !

បុរសជំនិតតបវិញតិចៗ៖

-ខ្ញុំករទេះសេះបី តែបានតែមួយទេ! រទេះផ្សេងទៀតមានតែសេះពីរឬមួយ! រទេះសេះបីនោះនឹងល្អអាចទុកចិត្តបាន! សម្រាប់អ្នកប្រុស និងអ្នកនាងឌីម៉ា!

នរិន្ទងក់ក្បាលតិចៗ។

ហួសពីផ្សារបន្តិច ពួកគេមកដល់ជម្រាលស្មៅមួយដែលមានរទេះសេះចំនួនបីចតចាំរួចជាស្រេច។ រាមនរិន្ទទទួលដបទឹកពីកងការពារមកក្រេបក្រោមជំនោររំភើយកណ្តាលធម្មជាតិបរិសុទ្ធ និងស្រស់បំព្រង។

"តើនេះជាកន្លែងចុងក្រោយរបស់បេសកកម្មឥន្ទប្បដិមាមែនឬក៏យ៉ាងណា? "គេសួរខ្លួនឯងស្ងាត់ៗ ហើយអង្គុយបង់ចំខែងទៅលើដង្កត់ឈើដោយមានកងការពារឈរអមច្រូងច្រាង។ អង្គរក្សរឿន ចាប់បើកកុំព្យូទ័រ ហើយអង្គុយលើខ្នងសេះធ្វើការអ្វីមួយដោយយកចិត្តទុកដាក់។ កងការពារម្នាក់ដើរទៅក្បែរដោយទឹកមុខស្ញើចសរសើរ គេនិយាយបែបហួសចិត្តៈ

-កោះស្មៅលឿង តែមានInternetប្រើគ្រាន់បើមែនទែន!

នាយរឿនងើបមុខសម្លឹងកូនចៅ គេនិយាយដោយម៉ត់ចត់ៈ

-អាគង់ទៅយូរម៉េះ? បើយើងមិនស្រូតទេ មុនថ្ងៃលិចយើងអាចនឹងរកភូមិនោះមិនឃើញ! ជិះសេះមិនមែនស្រួលដូចជិះឡានទេណ៎ា!

ឃើញនាយអង្គរក្សខ្វល់ខ្វាយ កងការពារសួរវិញភ្លាមៈ

-ខ្ញុំទៅតាមបងគង់ហ្អីបង?

នាយរឿនងើបមុខសម្លឹងបុរសនាយចៅហ្វាយជាបុត្រាទោលអ្នកនយោបាយដែលកំពុងអង្គុយសន្ទឹងជើងកាន់ដបទឹក និងបណ្តោយឲ្យភ្នែកទាំងគូមមីទៅតាមអំណាចខ្យល់។ រាមនរិន្ទនៅរក្សាបានភាពស្រស់សង្ហាទោះបីបបូរមាត់គេប្រែទៅជាក្រៀមស្ងួតរបកហើយសម្លៀកបំពាក់បោកបាចទៅតាមវាយោសន្ធាប់ក្តី។

រឿននិយាយតិចៗទៅកាន់មនុស្សក្រោមបង្គាប់ៈ

-អ្នកប្រុសមិនដែលហត់ដល់ម្លឹងទេ!

កងការពារដៀងភ្នែកទៅសម្លឹងចៅហ្វាយកំលោះដែលជានិច្ចកាលមានភាពប្រិមប្រិយលើផ្ទៃមុខ។ គេនិយាយតិចៗបែបកំប្លុកកំប្លែងៈ

-យ៉ាងណាក៏មិនអីដែរ ព្រោះចៅហ្វាយមានស្រីស្អាតមកតាម! អូនុះ បងគង់ហើយ!

អង្គរក្សរឿនងើបមុខមើលនាយគង់ដែលរត់មកពីចម្ងាយដោយគ្មានកេតឌីម៉ាតាមមកពីក្រោយ។

គេជ្រួញចិញ្ចើមហើយហក់ចុះពីលើសេះ ដើរជំហានវែងៗទៅរកគូកន។

-អាគង់! ឯណាកេតឌីម៉ា?

នាយគង់ប្រកបដោយទឹកមុខសស្លេកសស្លាំង។ គ្រាន់តែឃើញភ្នែកគេក៏ដឹងថាមានរឿងមិនល្អច្បាស់ណាស់។ នាយរឿនទាញអាវគេមកក្បែររួចសួរសង្ខេបដោយសំឡេងស្រាលៗក្នុងពេលរាមនរិន្ទដៀងភ្នែកសម្លឹងមក។

-មានរឿងអី?

អង្គរក្សគង់និយាយតិចៗដោយទឹកមុខបារម្ភ៖

-កេតឌីម៉ាបាត់ហើយ!

នាយរឿនក្រឡាប់គ្រាប់ភ្នែក គេសួរបញ្ជាក់ដោយអន្ទះសា៖

-ឯងថាម៉េច? មើលតែស្រីម្នាក់ហ្នឹង ឯងធ្វើអត់បានអាគង់?

នាយគង់ព្យាយាមពន្យល់ក្នុងពេលរាមនរិន្ទក្រោកដើរសំដៅមក៖

-កេតឌីម៉ាឲ្យខ្ញុំត្រឡប់មកទិញខោអាវស្រីឥស្លាមឲ្យ តែពេលខ្ញុំត្រឡប់ទៅដល់កប៉ាល់អត់ឃើញមានអ្នកណាម្នាក់នៅហ្នឹងទេ! គិតយ៉ាងម៉េចទៅ?

អង្គរក្សរឿនបញ្ចេញភាពស្មុគស្មាញលើផ្ទៃមុខ។ គេមិនទាន់បានវាចាថាម៉េចផង សំឡេងរាមនរិន្ទលាន់មកកាត់ផ្ដាច់ការសន្ទនាខ្សឹបៗរបស់អ្នកទាំងពីរ៖

-កេតឌីម៉ាមានរឿងអី?

បញ្ជាក់បន្ថែមពីលើការបង្ហាញខ្លួនរបស់គេដោយគ្មាននារីបង្ហាញម៉ូដតាមមកទៀតនោះ ទឹកមុខនាយគង់ដែលងាកមកជាចម្លើយស្រេចហើយមុនគេហើបមាត់ឆ្លើយទៅទៀត។

រាមនរិន្ទរក្សាភាពស្មើធេងលើផ្ទៃមុខក្នុងពេលសូរសំឡេងនាយរឿនលាន់មក៖

-ខ្ញុំទៅតាមរកមើលជិតៗនេះ យើងអត់មានពេលច្រើនទៀតទេ! កេតឌីម៉ាអាចថាចាំអាគង់យូរពេកបានចាកចេញពីកប៉ាល់មកតាមពួកយើង តែនាងអាចវង្វេងផ្លូវ!

នាយគង់ឈ្ងោកមុខរបៀបដឹងកំហុសតែមាត់ពោលរអ៊ុះការពារខ្លួន៖

-ខោអាវស្រីៗពិបាករកទិញណាស់! ទម្រាំរកបាន ដើរមិនចេះតិចផ្ទះទេ!

រាមនរិន្ទមិនទាន់ហើបមាត់ថាម៉េចផង នាយរឿនរលះរលាំងចេញទៅក្នុងទិសដៅតម្រង់ទៅកាន់ផ្សារកំពង់ដ។ ប៉ុន្តែសំឡេងត្រជាក់ស្រិបរបស់នាយBirdបានបង្អាក់គេៈ

-បងរឿន កុំទៅ!

គ្រប់គ្នាងាកមករកនាយBirdដែលកំពុងដើរមួយៗមកដោយទឹកមុខស្លេកស្លាំង។ អង្គរក្សរឿនរភ្នែកសម្លឹងមុខនាយBirdដែលនៅដំណាក់កាលសំខាន់បែរជាហ៊ានចេញមុខមកចាត់ចែង។ គេហាក់ចម្លែកចិត្តដែរ ប៉ុន្តែដោយសារស្ថានភាពពេលវេលា គេមិនមានពេលត្រិះរិះច្រើនក៏និយាយតបវិញផ្ទួងៈ

-មកនៅក្បែរអ្នកប្រុសមកអាBird! កេតឌីម៉ាប្រហែលនៅក្បែរនេះទេ!

គេងាកចេញ ហើយឈានញាប់ៗទៅ ប៉ុន្តែសំឡេងបុរសបង្កប់ខ្លួនលាន់មកតំណាលគ្នាក្នុងភាពសោះកក្រោះជាងមុនៈ

-បងរឿន! ស្រីនោះជារនុកក្នុងទេ!

អង្គរក្សរឿនប្រឹងឈានបន្តទៀត ប៉ុន្តែគេនៅតែទប់ដំណើរមកវិញ ព្រោះពាក្យមួយឃ្លាចុងក្រោយរបស់នាយBirdពិបាកឲ្យគេធ្វើពើជាមិនឮណាស់។

គេដៀងភ្នែកទៅរករាមនរិន្ទដែលកំពុងប្រែទឹកមុខ។ អង្គរក្សចំណាប់ចាប់សង្ខេញសួរនាយBirdជាបន្ទាន់ៈ

-ឯងកើតរោគឆ្កួតយកអីឯងអាBird?

តាមពិតអង្គរក្សរឿនមិនបានគិតដល់ទេថា រយៈពេលកម្សត់កម្រលើកំណាត់ផ្លូវដ៏វែងឆ្ងាយនេះ នាយបង្កប់ខ្លួនបានឆ្លងកាត់រឿងជាច្រើន រហូតដល់នាយBirdក៏ដូចជាមិត្តអ្នកអានដែរ គឺបានលង់ចិត្តលើកូនប្រុសអ្នកនយោបាយបាត់ទៅហើយ។

នាយKenជាថៅហ្វាយចាស់ដែលនាយbirdគួរណាស់តែមានភក្ដីភាពទោះបីជាខានបានទាក់ទងគ្នាមួយរយៈក៏ដោយ ប៉ុន្តែនាយBirdរឹតតែមិនដាច់ចិត្តពីរាមនរិន្ទទៅទៀត។ ចប់តាមផ្លូវចាប់តាំងពីចាកចេញពីភូមិភូវីខាន់ នាយBirdនៅតែតស៊ូ និងការប្រឆាំងគ្នារវាងគំនិតពីរគឺថាគួរនិយាយប្រាប់រាមនរិន្ទតាមត្រង់ ឬគួររក្សាការសម្ងាត់នេះជារៀងរហូតដើម្បីសុវត្ថិភាពខ្លួន។ ក្នុងពេលនាំគ្នាមក

សំចតក្បែរក្បួនរទេះសេះរង់ចាំដំណើរកេតឌីម៉ានេះទៀតសោត នាយBirdនៅសំងំស្ងៀមដើម្បីពិនិត្យពិច័យពីភូមិសាស្ត្រ។ ស្ថានភាពនៅចំពោះមុខ ធ្វើឲ្យគេយល់ថា អ្វីដែលរាមនរិន្ទកំពុងបោះជំហានទៅរក គឺហាក់ដូចជាមានគ្រោះថ្នាក់ច្រើនជាសំណាងល្អ។ បន្ទុះនៅWinter JayaPuraនិងអន្ទាក់នៅភូមិភូរីខាន់ ធ្វើឲ្យរូបភាពអាក្រក់ៗរបស់ក្រុមកុលសម្ព័ន្ធនៅតែតាមលងក្នុងចិត្តអ្នកការពារទាំងឡាយ គ្រាន់តែពួកគេមិនហ៊ានសម្ដែងចេញ ព្រោះគេដឹងច្បាស់ថាគ្មានអ្នកណាអាចទប់ស្កាត់ថៅហ្វាយប្រុសរបស់គេពីការរុលទៅរកវត្ថុនោះឡើយ។ នាយBirdយល់ថា ហេតុការណ៍អាក្រក់ពីរខាងដើម គឺរាមនរិន្ទអាចឆ្លងកាត់បាន ប៉ុន្តែអ្នកណាអាចធានាថាគេនឹងមានសុវត្ថិភាព និងសំណាងបែបនេះរហូតនោះ។ នាយបង្កប់ខ្លួនកាន់តែគិតកាន់តែស្មុគស្មាញ់ថា ពេលនេះរាមនរិន្ទយកកេតឌីម៉ាមកតាមគ្រប់ជំហាន ទោះបីនាងមិនដឹងថាខ្លួននាយBirdជាជនបង្កប់ ប៉ុន្តែនាយដឹងរឿងនាងច្បាស់ថានាងជាសង្សាររបស់ពាណិជ្ជករKenចំណែកការដែលមករស់ក្បែរកូនប្រុសអ្នកនយោបាយគឺដើម្បីតែស៊ើបការណ៍ប៉ុណ្ណោះ ហេតុនេះនាយបង្កប់ខ្លួនយល់ថា ទោះរាមនរិន្ទមានសំណាងបានចេញពីកោះស្មៅលឿងជាមួយឥន្ទប្បដិមា តែគេនៅមានឧបសគ្គដ៏ធំមួយទៀត គឺចារនារី ដែលនៅក្បែរខ្លួនគេ។ រឹតតែគួរឲ្យសង្ស័យនោះ នៅសុខៗនាងក៏ស្រាប់តែបាត់ខ្លួន។ ភាគរយដែលថានាងអាចនឹងទាក់ទងជួបពាណិជ្ជករដែកថែបដើម្បីបង្កើតគម្រោងការណ៍អាក្រក់ចំពោះរាមនរិន្ទ។ នាយBirdគិតច្បាស់ណាស់មុនពេលសម្រេចចិត្តថាត្រូវបកអាក្រាតនាង មុនពេលដែលនាងបង្កើតបញ្ហាដល់បុរសចិត្តមាសរាមនរិន្ទ។

-អ្នកប្រុស! កេតឌីម៉ាតាមពិតគឺថៅកែ Kenប្រើឲ្យមកទេ!

អង្គរក្សរឿនស្ទុះមកក្របួចកអាវនាយBirdប៉ុន្តែត្រូវបុរសបង្កប់ប្រឆាំងវិញពេញទំហឹង ដែលធ្វើឲ្យម្នាក់ៗនៅទីនោះទៅជាស្រឡាំងកាំង ព្រោះកន្លងមកកងការពារទាំងឡាយតែងគោរពនាយរឿនណាស់។

រាមនរិន្ទបើកភ្នែកធំៗសម្លឹងអង្គរក្សបង្កប់ខ្លួនដែលឥឡូវនេះបញ្ចេញមុខមាត់ពិត លែងត្រុនៗ លែងលិបលុ តែក្លាហានមកប្រឈមចំពោះមុខខ្លួន។ សំឡេងនាយBirdលាន់ច្បាស់ៗមកកាន់កូនប្រុសអ្នកនយោបាយ ក្នុងពេលដែលនាយរឿន និងនាយគង់ស្ទុះមកក្បែរដើម្បីការពារថៅហ្វាយខ្លួន៖

-អ្នកប្រុស! ឈប់ជឿស្រីនោះទៅ! ដើម្បីសុវត្ថិភាពអ្នកប្រុសឈប់ឲ្យកេតឌីម៉ាមកនៅក្បែរខ្លួនទៀតទៅ! ខ្ញុំធ្វើនេះដើម្បីអ្នកប្រុស គឺខ្ញុំស្រលាញ់អ្នកប្រុស!

នាយរឿនសម្លឹងនាយBirdមិនព្រិចភ្នែកដើម្បីឲ្យដឹងថាតើគេកំពុងនិយាយពិតឬកុហក ប៉ុន្តែរាមនរិន្ទដែលប្រែទឹកមុខទៅជាស្មើធេង បែរជាបន្លឺឡើងមួយៗតបនឹងសេចក្ដីរាយការណ៍ដ៏គួរឲ្យរន្ធត់នោះ៖

-បើអញ្ចឹង! បង្ហាញភស្តុតាងមក!

នាយគង់បន្ទរទាំងគំហក៖

-ត្រូវហើយ! បង្ហាញភស្តុតាងមក!

នាយBirdងក់ក្បាលផ្ញក់ៗ៖

-បាន! គឺខ្ញុំនេះហើយជាភស្តុតាង! ព្រោះ....ព្រោះថា ខ្ញុំក៏ជា....ក៏ជា...ក៏ជាមនុស្សដែលថៅកែ Ken ប្រើម៉ោដូចគ្នា!

អង្គរក្សរឿនបើកភ្នែកធំៗ តែរាមនរិន្ទរេភ្នែកសម្លឹងទៅទីផ្សេង។ គេនៅស្ងៀមមិនចេញស្ដី ប៉ុន្តែនាយBirdយល់ហើយថារាមនរិន្ទចង់ស្ដាប់រឿងនេះឲ្យច្បាស់មុនពេលសម្រេចចិត្ត។

នៅសុខៗ វា គ្មានហេតុផលអ្វីផ្សេងដែលនាយBirdត្រូវមកនិយាយលេងសើចក្នុងកាលៈទេសៈដ៏សំខាន់នោះទេ ។នេះជា អ្វីមួយដែលអ្នកប្រុសធំគ្រួសារអ្នកនយោបាយគិត ឃើញ។ដូច្នេះហើយបានជាគេព្រមយកចិត្តទុកដាក់ជាមួយរឿងដ៏គួរអោយក្ដៅចិត្តនេះ។

ជនបង្កប់ចាប់ផ្ដើមដាក់បេះដូងចុះចូលជាមួយកូនប្រុសអ្នកនយោបាយតាំងពីរាត្រីដែលនាយហក់ទៅក្នុងទឹកទាំងដៃមានរបួសដើម្បីជួយជីវិតខ្លួន គ្រាន់តែថាការសម្រេចចិត្តបើកកាយពីសមាសភាពកេតឌីម៉ានៅអូសបន្លាយដោយសារនាយBirdនៅបារម្ភពីសុវត្ថិភាពខ្លួនក្រោយពីអ្នកផងដឹងរឿងពិត។ប៉ុន្តែសម្រាប់ស្ថានភាពចុងក្រោយនេះគឺជារឿងផ្សេង។ ការមកដល់គោលដៅប្រកបដោយគ្រោះថ្នាក់ដែលនាយKenបានមកដល់មុនមួយជំហាន គ្មាននរណាដឹងថារាមនរិន្ទអាចនឹងប្រឈមគ្រោះកាចអ្វីខ្លះទេ ពិសេសនៅសុខៗកេតឌីម៉ាស្រាប់តែបាត់មុខទៀត នាយBirdកាន់តែអន្ទះសា។ នៅទីបំផុតទោះមួយចានស្លាប់មួយចានរស់ គេត្រូវតែបកអាក្រាតការពិតអោយបុរសដែលគេកោតគោរពបំផុតអាចការពារខ្លួនបានទាន់ពេល។

នៅពេលត្រូវគេទារក ភស្តុតាងនាយបង្កប់បានរំលឹកឡើងវិញទាំងអស់ រាប់ទាំងស្នេហារបស់ស្រីអ្នកបង្ហាញម៉ូត និងពាណិជ្ជករនៃសហគ្រាសCam steel ការបញ្ជូនផ្កាSaffronដល់បន្ទប់នាង ការឲ្យថ្នាំនាងមួយដបមកកាន់ Amandariនិងរឿងគ្រប់យ៉ាងដែលធ្វើឲ្យអតីតកាលដ៏ឈឺចាប់របស់ស្រី

ស្អាតត្រូវបានលាតត្រដាងមកវិញច្បាស់ដូចថ្ងៃ ធ្វើឲ្យអង្គរក្សរឿនធ្លាក់ថ្លើមក្តុកក្នុងពេលកងការពារឯទៀតចំហមាត់ផ្លុង។

នាយរឿននឹកឃើញឡើងវិញដល់ពេលដែលពាណិជ្ជករដែកថែបបង្ហាញខ្លួននៅឯកន្លែងដេញថ្លៃ គេពិតជាមានចរិតក្រអឺត និងប្រកបដោយជំនឿចិត្តណាស់។ គេហ៊ានមករលាក់ដៃជាមួយរាមនរិទ្ធ និងចេញមុខប្រជែងគ្នាដោយបើកចំហ តាមពិតគេបានរៀបចំក្រឡាលើយ៉ាងល្អិតល្អន់រួចមកហើយ  ប៉ុន្តែដែលគួរឲ្យអាណិតនោះ គឺនាគរាជបានលង់នឹងសម្រស់ស្រីធ្វើឲ្យបាក់ឫទ្ធិដោយស៊ុសន្ទូចគេរហូតមកដោយមិនដឹងខ្លួន។ ពេលនេះមកជាន់ដីកោះអាថ៌កំបាំងទៀត ក៏មនុស្សរបស់គេនៅបង្កប់ត្រៀបត្រា មិនដឹងថាតើវាសនាថៅហ្វាយប្រុសស្មោះស្នេហ៍របស់ខ្លួននឹងជួបជំពប់រឿងអកុសលអ្វីខ្លះនោះទេ។ កងការពារម្នាក់ផ្ទុះសម្តីដោយកំហឹង៖

-អញ្ចឹងបានមកដល់កោះនេះភ្លាមបាត់ខ្លួនភ្លែត! ស្រីនោះសមតែសម្លាប់ចោលទេ!

នាយរឿនដៀងភ្នែកលួចមើលមុខថៅហ្វាយប្រុសដែលនាយយល់ថាកំពុងជឿសម្តីនាយBirdដោយឥតសង្ស័យទៅហើយ។ ទោះគេនៅរក្សាទឹកមុខស្មើ តែមនុស្សជំនិតដឹងថាគេកំពុងខូចចិត្តជាទីបំផុត។

ប្រសិននាងចូលមកត្រឹមឋានៈជាមនុស្សបង្កប់ ការវែកមុខនាងមិនមែនជារឿងធំដុំទេ ប៉ុន្តែនាងជាមនុស្សដែលរាមនរិទ្ធស្រលាញ់ ហើយស្រលាញ់ជាទីបំផុត ម៉េចក៏នាងមានប្រវត្តិប្រឡាក់ប្រឡូសបេះដូងជាមួយពាណិជ្ជករមានល្បិចកលនោះ ?

"កេតឌីម៉ាអើយកេតឌីម៉ា?នាងសុខចិត្តធ្វើរឿងក្បត់ចិត្តមនុស្សល្អដើម្បីតែមនុស្សអាក្រក់?តើនាងល្ងង់រឺក៏នាងឆ្កួត?"។អង្គរក្សដែលយល់ការជាងគេគិតផងផ្តោតភ្នែកទៅរកមុខរបួសដែលលាក់ក្នុងអាវអ្នកប្រុសសង្ហាដោយសារស្នាដៃស្រី ស្អាតនៅឡើយ។គេចាប់ផ្តើមស្លុងចិត្តអាណិតអ្នកប្រុស ធំហើយអារម្មណ៍កាន់តែសៅហ្មងប៉ងតែកាប់ ចិញ្ច្រាំអភិជនKen។

-នោះកេតឌីម៉ាហ្នក់!

នាយគង់ភ្លាត់មាត់ធ្វើឲ្យអ្នកផងងាកទៅសម្លឹងរកប្រភពដែលស្រីបង្ហាញម៉ូដមិនដឹងខ្លួនថាត្រូវគេបកអាក្រាតហើយកំពុងរត់ត្រុកៗមករកម្ចាស់បេះដូង។

រាមនរិទ្ធមិនងាកសម្លឹងនាងទេ ព្រោះទោះមាំទាំយ៉ាងណា គេនៅតែមិនអាចទទួលយកការពិតនេះហើយមិនអាចធ្វើពើជាមិនដឹងមិនឮទៀតបានឡើយ។ អ្នកប្រុសនាំកាយខ្ពស់សង្ហាដើរមួយៗទៅរក

ជំនិះដែលកំពុងបញ្ឈរចាំ ហើយឈានជើងសំដៅឡើងជិះលើរទេះសេះ ក្រោមក្រសែភ្នែកពោរពេញដោយកង្វល់របស់អង្គរក្សរឿន។

ភាគទី៤៣

ពន្លឺភ្នែកកងការពារទាំងឡាយដែលប្រែទៅជាមិនសប្បាយចិត្ត ហើយសម្លឹងស្រុះគ្នាមកខ្លួនធ្វើឲ្យនារីនឹកឆ្ងល់ដែរ ប៉ុន្តែដោយសារបារម្ភពីសុវត្ថិភាពប្រុសស្នេហ៍កេតឌីម៉ាគ្មានពេលរវល់នឹងពួកគេទេ នាងគិតតែពីតាមសម្លឹងនរិន្ទដែលឈានឡើងរទេះហើយហាក់មិនខ្វល់នឹងនាង។ បបូរមាត់ស្រីនិយាយព្នាៗទៅកាន់នាយដោយសារតែអន្ទះសាពេក៖

-លោកប្រុសរាម លោកកុំទៅជួបលោកវ៉ាទូអី!

អ្នកប្រុសឈប់ង៉ក់នៅក្បែររទេះ គេសើចស្ងួត ហើយឆ្លើយតបដោយមិនខ្ចីទាំងងាកមកសម្លឹងនាង៖

-មកដល់ទីនេះហើយ នាងនៅគិតថាចង់ឃាត់ខ្ញុំទៀតកេតឌីម៉ា?

ស្រីស្រស់ស្ទុះចូលទៅក្បែរគេភ្លាមព្រោះមិនដឹងទេថាហេតុអ្វីគេបែរទៅជាសោះអង្គើយ។ នាងឈានទៅក្នុងពេលក្រុមកងការពារស្ទុះមកស្រតំណាលគ្នាព្រោះក្នុងកែវភ្នែកពួកគេ នាងបានក្លាយទៅជាសត្រូវគំរាមកំហែងសន្តិសុខរាមនរិន្ទធំជាងគេ។

នាយគង់ស្ទុះមកពាំងពីមុខស្រីស្អាតដែលឡិងឡង់ព្រោះមិនយល់រឿង។ សូម្បីតែចូលទៅក្បែរប្រុសកំពូលស្នេហ៍ក៏នាងអស់សិទ្ធិដែរ។ ឌីម៉ារវេភ្នែកសម្លឹងមនុស្សម្នាដែលសម្លឹងមកនាងហាក់ខឹងសម្បា។ នាងងាកមកសួរនាយគង់វិញ៖

-បងគង់? មាន...មានរឿងអី?

នាយគង់សម្លក់នាងចុងភ្នែករួចងាកទៅកន្លែងផ្សេងហាក់មិនចង់សូម្បីតែឆ្លើយតប។ នារីរវេភ្នែកទៅរកអង្គរក្សរឿន ឃើញគេធ្វើមុខស្មើដូចកំពុងខំទប់ចិត្តណាស់ នាងដឹងថាបើនាងសួរនាំគេ គេមុខតែបញ្ចេញកំហឹងនោះចេញមកមិនខាន ម៉្លោះហើយទីសម្អាងចុងក្រោយរបស់នារីយើង នៅតែជាបុរសដែលមានអំណាចជាងគេនៅទីនេះ។

នាងងាកមករកគេដែលឈរបែរខ្នង ល្មមពេលព្រាមនរិន្ទនិយាយមកសោះកក្រោះ៖

-ទៅរកចៅហ្វាយល្អរបស់នាង ហើយប្រាប់គេថាឲ្យឈប់លេងល្បិចថោកទាបអស់នេះទៅ បើមិនអញ្ចឹង កុំថាឥន្ទប្បដិមា ជីវិតវាក៏ប្រហែលគ្មានត្រឡប់ទៅវិញដែរ!

តរុណីស្រឡាំងកាំងចំពោះសម្ដីអសុរសរបស់គេដែលនាងទើបតែឮជាលើកដំបូង ពិសេសពាក្យប្រមាថដល់ជីវិតដែលគ្មានអ្នកណាគិតថានឹងបង្ហើរចេញពីមាត់កូនប្រុសអ្នកតំណាងរាស្ដ្រនេះរួចទេ។

គេឡើងទៅលើជំនិះ ចោលនាងដែលឈរទ្រឹងព្រោះភាន់ភាំង។ នាងងាកមើលមនុស្សជុំវិញខ្លួនស្របពេលសំឡេងនាយគង់និយាយមកម្ដង៖

-កេតឌីម៉ា! បើនាងជួបថៅកែ Kenប្រាប់គេឲ្យដឹងខ្លួនផង អាល្បិចកំសាកអញ្ចឹង វាគ្មានបានការអីទេ។

នាងងើបមុខសម្លឹងអង្គរក្សរូបនោះដោយរន្ធត់ និមិត្តឮគេបង្ហើបពីឈ្មោះ Ken។ សំឡេងគេជះមកកាន់នាងសាជាថ្មី៖

-ហើយកុំយកអាភាពស្មោកគ្រោករបស់នាង មករញ៉េរញ៉ៃក្បែរអ្នកប្រុសទៀត! នាងសមគ្នាហើយជាមួយមនុស្សល្បិចដូចគ្នាហ្នឹង!

ឌីម៉ាធ្លាក់ថ្លើមដូចត្រូវគេសំពង។ "កាយវិការពួកគេដូចជាកំពុងដឹងឮពីអតីតកាលរបស់យើងអស់ហើយ។ ហេតុអ្វី? អ្នកណាធ្វើ? ប៉ុន្តែអត់សំខាន់ត្រង់អ្នកណានិយាយទេ សំខាន់គឺយើងពិតជាមានរឿងគួរឲ្យអៀនខ្មាសអស់ហ្នឹងមែន! ពុទ្ធោ រាមនរិន្ទខឹងយើងយ៉ាងណាទៅ? ហេតុអីបែរជាគេមកដឹងរឿងក្នុងកាលៈទេសៈនេះទៅវិញ! វាជាពេលដែលគេត្រូវជឿយើងដើម្បីគេចពីអន្ទាក់ពួកកុលសម្ព័ន្ធ"

មាណវីបែរទៅរករាមនរិន្ទវិញមួយរំពេច។ បុរសមានអំណាចអង្គុយផ្ទឹងម្នាក់ឯងលើជំនិះ ដែលមុននេះគេគិតថានឹងបានកម្សាន្តធម្មជាតិជាមួយស្រីដែលខ្លួនស្រលាញ់ព្រមទាំងទើបតែបានចុះកិច្ចសន្យាស្នេហ៍ថ្មីៗកាលពីរាត្រីម្សិល។ នារីចង់ស្ទុះចូលទៅរកគេដើម្បីពន្យល់ ប៉ុន្តែអង្គរក្សគង់មិនបានទុកឲ្យនាងសូម្បីតែឱកាសនេះឡើយ។

គេច្រាននាងចេញ ល្មមពេលឮវាចាម្ចាស់ប្រុសពីលើរទេះ៖

-យើងចេញដំណើរទៅ!

រទេះសេះគេបំបោលចេញត្រឹកៗធ្វើឲ្យនារីរឹតតែស្លន់ស្លោ។ នាងចាប់រលីងរលោងទឹកភ្នែក តែនៅបន្តមានះរត់ចូលទៅក្បែរគេ ព្រោះអង្គរក្សគង់ និងរឿនបានឡើងទៅលើរទេះទី២បាត់ហើយ។ នាងរត់តោងតាមជំនិះដែលកូនប្រុសអ្នកនយោបាយដាច់ចិត្តមិនព្រមសូម្បីតែសម្លឹងមកនាង។ នាងដឹង

ថា គេខឹងត្រូវ ព្រោះនាងមានអ្នកដទៃមុនពេលមានគេ ហើយព្យាយាមលាក់គេរហូតមក ពិសេសម្នាក់នោះជាគូបដិបក្ខរបស់គេទៀត។ ប៉ុន្តែពេលនេះ ចំពោះមុខគឺនាងមិនមែនចង់សុំឲ្យគេអភ័យទោសទេ គឺចង់ឲ្យគេឈប់ទៅរកពួកកុលសម្ព័ន្ធ ព្រោះលំអងបានប្រាប់នាងពីរឿងអកុសលទាំងឡាយដែលពាណិជ្ជករដែកថែបបានរងជាមុនរួចទៅហើយនោះ។

ស្រីស្រស់និយាយទៅកាន់បុរសដោយទឹកភ្នែក៖

-កុំទៅអី! ខ្ញុំសូមអង្វរ! កុំទៅកន្លែងនោះ!

រាមនរិន្ទមិនងាកមើលនាង ព្រោះគេដឹងថាស្រីម្នាក់នេះបានប្រើទឹកភ្នែកនាងជានិច្ចកាលឲ្យអ្នកទន់ចិត្ត។ សូម្បីតែតបមួយម៉ាត់ក៏គេលែងតប ព្រោះយល់ថាវាគ្មានប្រយោជន៍អ្វីក្នុងការនិយាយខុសត្រូវជាមួយជំពូកមនុស្សមានកលទៀយ។ ណាមួយខ្លួនជាភាគីចាញ់ស្នេហ៍ ឋានៈ បញ្ញា និងរូបរាងប៉ុណ្ណឹងដែរ មកឲ្យនារីខ្វាត់ព្រាត់ម្នាក់បោកប្រាស់ដឹកច្រមុះបានរហូតមក ក៏ល្មមឲ្យទទូរដីគេចពួកបរិវារទៅហើយ ទម្រាំឲ្យមកស្ដាប់នាងនិយាយទៀត មានតែបន្ថែមការអាម៉ាស់ឲ្យខ្លួនឯងប៉ុណ្ណោះ។

នៅជាមួយគ្នា រួមកាយរួមជីវិត ទោះបីរយៈពេលខ្លី តែនាងដឹងចិត្ត និងយល់ពីអារម្មណ៍គេច្បាស់ នាងមិនបានខឹងតប តែបែរជាយល់ថាធ្វើខុសចំពោះគេធ្ងន់ពិបាកឲ្យលើកលែងណាស់។

"កេតឌីម៉ា! ស្រីល្ងង់ ស្រីឆ្កួត! បើលើកនេះឯងមិនអាចបញ្ឈប់គេ ហើយបណ្ដោយឲ្យគេទៅ ឯងអាចនឹងលែងបានឃើញគេរហូតហើយ" នាងគិតទាំងងឹតឈឹងក្នុងអារម្មណ៍។ ដោយក្ដីអន្ទះសា នាងស្រវាតោងដៃរាមនរិន្ទពីក្រៅរទេះដែលកាន់តែបង្កើនល្បឿន។ បុរសមិនចង់ឃើញនាងសូម្បីមួយវិនាទីទៀតនោះ ចង់ដកដៃមកវិញភ្លាមៗតាមកំហឹង និងការខូចចិត្ត ប៉ុន្តែគេនៅតែមិនដាច់ចិត្ត ព្រោះគេដឹងថាបើគេលែងដៃ នាងនឹងដួលច្រងាប់ច្រងិលហើយ។

បានឱកាស ស្រីកម្សត់និយាយទៅកាន់គេ៖

-អូនឈប់ស្រលាញ់គេហើយ! គេជាមនុស្សអាក្រក់ គេគ្មានត្រង់ណាផ្ទឹមជាមួយបងបានទេ! ចាប់ពីពេលដែលអូនសម្រេចចិត្តមកកោះស្មោះលឿង គឺអូនស្រលាញ់បងទៅហើយ! អូនសូមទោស!រាមនរិន្ទ អូនសូមទោស! បងកុំទៅកន្លែងនោះអី! អូនសូមអង្វរ!

បុរសតណ្ហាណោស៊ីដែលបញ្ញាសេះឃើញកាយវិការនាងគួរឲ្យអាណិតទោះមិនអាចស្ដាប់យល់សម្ដីនាង តែគេក៏ចង់បង្អាក់អាជានេយ្យមកវិញដែរ តែឃើញរាមនរិន្ទកាន់ដាច់ណាត់យ៉ាងនេះ គេឯណាហ៊ាន មានតែបន្ថយល្បឿនកុំឲ្យស្រីស្អាតដួលតែប៉ុណ្ណោះ។

រាមនរិន្ទវិញ ក៏ក្តុកក្តួលចិត្តពេលឮសម្តីផ្អែមល្ហែមចេញពីមាត់នាងជាលើកដំបូង។ យូរហើយនាងមិនដែលប្រើពាក្យអូន ហើយក៏មិនដែលនិយាយច្រើនអីយ៉ាងនេះដែរ តែហៀបនឹងទន់ចិត្តកាលណា សម្តីផ្អែមល្ហែមរបស់នាងដែលឆ្លើយឆ្លងទូរសព្ទជាមួយជនមិនស្គាល់មុខនៅក្នុងបន្ទប់នាងនៅក្រុងJayaPuraដែលខ្លួនធ្លាប់ច្រលំថាជាសិទ្ធិគុណ លេចឡើងមកក្នុងអារម្មណ៍កូនប្រុសអ្នកតំណាងរាស្ត្រ។ គេនៅចាំថាកាលណោះត្រឡប់មកពីបឹងសេតានីវិញ នាងបានទូរសព្ទផ្អែមល្ហែមប្រាប់ប្រុសម្នាក់តាមទូរសព្ទដោយប្រើពាក្យបងអូនពេញមាត់ ដូចពេលនេះដែរ។

បុរសមានអំណាចគិតក្នុងចិត្តដោយក្តៅក្រហាយៈ

"តាមពិតគឺនិយាយទូរសព្ទផ្អែមល្ហែមជាមួយអាKenហើយជួយនាំដំណឹងគ្រប់យ៉ាងឲ្យវា រហូតដល់វាតាមមកចាយ៉ាពូរ៉ា ហើយឡើងដល់កោះស្មៅលឿងបានមុនទៀត។ កោតតែយើងខំស្រលាញ់នាង ទុកចិត្តនាង ប្រថុយទាំងជីវិតដើម្បីជួយនាង ច្រឡំស្រីមានល្បិចមាយា១០០ជំពូកដូចនាងថាជាស្រីស្មោះត្រង់ស្លូតបូត។ ″

ស្ទើរស្រក់ឈាមតាមភ្នែក បុរសអភិជនបេះម្រាមដៃនាងចេញបណ្តោយឲ្យរាងកាយទន់ល្វក់ដូចល្ងាចេកដែលអ្នកធ្លាប់តែឱបត្រកងពេញរង្វង់ដៃទ្រេតទ្រោតចេញពីរទេះ បាត់ជំហរហើយដួលទ្រោបទៅលើកម្រាលស្មៅ។

គេចេញដំណើរទៅចោលនាងទាំងហេងហាងក្នុងចិត្ត។ រទេះរបស់គេចេញឆ្ងាយទៅៗ ប៉ុន្តែមានរទេះថ្មីមួយទៀតមកឈប់ង៉ក់នៅចំពោះមុខនាងម្តង។

ភ្នែកនាងព្រិលដោយអំណាចជលនេត្រ ប៉ុន្តែនាងនៅមើលស្គាល់ថាបុរសជិតស្និទ្ធបំផុតរបស់រាមនរិន្ទ

កំពុងឱនសម្លឹងមកនាង។ ស្រីស្រស់រលះរលាំងក្រោកមកក្បែរនាយអង្គរក្សដែលមានផ្ទៃមុខស្មើធេង គ្មានសញ្ញាថាខឹង ឬសប្បាយ ដូចទឹកមុខទឹកករបស់រាមនរិន្ទដូច្នោះដែរ។ នៅក្បែរអង្គរក្សរឿន នាយគង់កំពុងអង្គុយដោយមុខក្រហមង៉ូវ។ ទោះបីដឹងថាកំហុសជាជនបង្កប់ និងជាស្រីបោកប្រាស់អាចនឹងធ្វើឲ្យនាងប្រឈមមុខចំពោះទណ្ឌកម្មពីក្រុមកងការពារ ប៉ុន្តែនាងនៅតែទុកសុវត្ថិភាពរាមនរិន្ទជាអាទិភាព។ ក្នុងថេរៈវេលាដែលប្រថុចញ៉ុច នារីនិយាយទៅកាន់ពួកគេ ទោះបីនាងគិតថានាយគង់អាចដាក់ទោសអំពើក្បត់របស់នាងដោយគ្រាប់សំណដែលគេកំពុងសៀតនៅចង្កេះដូចកាលពីក្នុងព្រៃដែលនាងចាក់ថៅហ្វាយប្រុសគេក៏ដោយ។

ប៉ុន្តែនាងមិនទាន់ហារមាត់បានផង អង្គរក្សរឿនហុចដៃគេមកចំពោះមុខនាង។ ដោយភ្ញាក់ផ្អើល នាងងើបមុខសម្លឹងគេ ក្នុងពេលគេនិយាយកំបុតកំបុយ៖

-ឡើងមក!

មិនត្រឹមនាងបង្ហាញម៉ូតទេដែលស្រឡាំងកាំង សូម្បីតែនាយគង់នៅក្បែរនោះក៏នៅមិនសុខដែរ គេសួរភ្លាមដោយសំឡេងខ្លាំង៖

-បងឯងនាំស្រីនេះទៅធ្វើអី?

ភាពរីករាយផុសចេញតាមពន្លឺភ្នែកនារីដែលកំពុងអស់សង្ឃឹម នាងស្រវាតោងដៃអង្គរក្សរវៃឆ្លាត ហើយយោងខ្លួនឡើងទៅលើរទេះ។

ដោយមានការជួយទាញពីបុរសនោះ នាងបានមកដល់ខាងលើភ្លាម ធ្វើឲ្យនាងធូរចិត្តមួយរំពេច ប៉ុន្តែបុរសម្នាក់ទៀតចាប់បញ្ចេញកាយវិការច្រឡោតតោតតូង។ គេស្ទុះចោលទីនោះទៅកាន់រទេះទី៣ជាមួយកូនចៅឯទៀត បង្ហាញច្បាស់ថាគេស្អប់មិនចង់មើលមុខ និងមិនចង់ខ្សល់ដង្ហើមរបស់ស្រីដែលក្បត់ចៅហ្វាយគេទេ។

ឪម៉ាដែលអង្គុយក្បែរអង្គរក្សខ្ពស់ស្រាវ តាមសម្លឹងដំណើរនាយគង់ពីក្រោយ ទន្ទឹមពេលដែលរទេះសេះចាប់ចេញដំណើរសាជាថ្មី។

នាងបោះបង់ចោលការយកចិត្តទុកដាក់ចំពោះនាយគង់ដោយងាកមកដោះស្រាយស្ថានការណ៍ចំពោះមុខ។ ឪម៉ាងាកមកអង្វរនាយជំនិតរបស់ប្រុសស្នេហ៍ភ្លាម៖

-ជួយឃាត់គេផងទៅ! កុំទៅកន្លែងនោះអី! ណា៎! ជឿខ្ញុំទៅ!

អង្គរក្សរឿនសើចខឹកក្នុងទ្រូង។ គឺជាសំណើចចំអកដែលធ្វើឲ្យនារីតឹងចិត្ត។ គេនិយាយមកតិចៗទាំងភ្នែកសម្លឹងទៅគោលដៅខាងមុខ៖

-កេតឪម៉ា! នាងគិតថាអាចដណ្ដើមតន្ទប្បដិមាពីដៃអ្នកប្រុសទៅឲ្យអាចៅកែដែកនោះអញ្ចឹងអ្ហេស?

ស្រីស្អាតទើបតែដឹងថា ការពិតដែលគេម្នាក់ៗមិនព្រមយកចិត្តទុកដាក់ចំពោះសម្ដីខ្លួន ក៏មកពីគេគិតថានាងជាមនុស្សបង្កប់របស់នាយKen។ វាចាអម្បាញ់មិញរបស់អង្គរក្សរឿនបញ្ជាក់ស្រេចហើយថា ម្នាក់ៗកំពុងយល់ខុសពីការពិតដែលនាងយកមកនិយាយក្នុងពេលនេះ។ ដោយសារ

កំហឹងពួកគេយល់ថា សម្ដីនាងដែលឃាត់ដំណើរថៅហ្វាយគេ គ្រាន់តែជាល្បិចប្រឌិតឡើងដើម្បីឃាត់រាមនរិន្ទកុំឲ្យទៅប្រជែងយកឥន្ទប្បដិមាជាមួយនាយKenតែប៉ុណ្ណោះ។

ដោយតូចចិត្តដែលខ្លួនខំស្មោះត្រង់យ៉ាងនេះ ក៏នៅតែគ្មានគេព្រមជឿ ឌីម៉ាពន្យល់ទៅអង្គរក្សរឿនផង យំអណ្ដឺតអណ្ដកផង៖

-រឿន! កាលពីមុនខ្ញុំមិនស្គាល់ចិត្តថៅហ្វាយលោក ខ្ញុំត្រូវលំអង និងថៅកែKenបោកប្រើ! តែរយៈពេលកន្លងមកដែលខ្ញុំមកនៅជិតអ្នកប្រុសលោក ខ្ញុំបានតាំងចិត្តថាស្រលាញ់តែគេម្នាក់គត់ ចិត្តខ្ញុំអត់មានអ្នកណាទៀតទេ! លោកជឿខ្ញុំទៅ!

អង្គរក្សរឿនងាកមកសម្លឹងនាង គេនិយាយដោយទឹកមុខម៉ឹងម៉ាត់៖

-ខ្ញុំយកនាងមកជាមួយព្រោះចង់បញ្ជាក់រឿងហ្នឹងហើយ! បើនាងស្មោះមែន ខ្ញុំជឿនាង!

ឌីម៉ាត្រេកអរក្នុងពោះ នាងបញ្ជាក់សួរភ្លាម៖

-ធ្វើម៉េច? លោកឲ្យខ្ញុំធ្វើម៉េចទៅ? និយាយមក!

រឿនសើចស្ងួត តែជាសំណើចកាចសាហាវ៖

-នាងសម្លាប់អាចង្រៃនោះ! ខ្ញុំនឹងព្រមជឿនាងកេតឌីម៉ា!

ផ្ទៃមុខអ្នកគ្រូបង្ហាញម៉ូដប្រែទៅជាស្លេកស្លាំង។ នាងនៅភាន់ភាំង តែអង្គរក្សរូបនោះងាកមកសម្លឹងនាងជាសញ្ញាសួរបញ្ជាក់ថា តើនាងគិតយ៉ាងម៉េច?

នាងគ្រវីក្បាលយឺតៗនៅចំពោះកែវភ្នែកមុតថ្លារបស់នាយអង្គរក្ស រួចនិយាយតម្អូញ៖

-រឿន! លោកដឹងហើយថា ខ្ញុំមិនអាចធ្វើរឿងអញ្ចឹងកើតនោះទេ!

ទីបំផុតអង្គរក្សរឿននៅតែរកមិនឃើញភាពកាចសាហាវនៅក្នុងចរិតលក្ខណៈរបស់ស្រីម្នាក់នេះទេ ប៉ុន្តែប្រហែលជារឿងរ៉ាវកើតឡើងហាក់ដូចជាច្របូកច្របល់ពេកសម្រាប់នាយ ទើបនាយគំហកមកកាន់នាងសាជាថ្មី៖

-បើនាងស្រលាញ់អ្នកប្រុស មានរឿងស្អីដែលថាធ្វើមិនបាន? នាងហ៊ានដល់ថ្នាក់ដាក់ថ្នាំសន្លប់ឲ្យអ្នកប្រុសនៅAmandari ហ៊ានយករឿងដែលពួកយើងនិយាយគ្នាទៅប្រាប់វានោះ នាងធ្វើល្បិច

ដើម្បីវានោះបានទាំងអស់ ហេតុអ្វីឥឡូវនាងសម្លាប់វាដើម្បីអ្នកប្រុសវិញមិនបាន? កោតតែអ្នកប្រុសមកស្រលាញ់មនុស្សឡប់សតិដូចនាងកេតឌីម៉ា!

នារីដែលកំពុងស្ថិតនៅក្នុងស្ថានភាពទាល់ច្រក ឈ្ងោកមុខបង្ហូរទឹកភ្នែកទទួលយកពាក្យប្រមាថរបស់នាយបរិវារដែលពីមុនមកគេមិនដែលហ៊ានប្រើចំពោះនាងឡើយ។ នាងយំខ្សឹកខ្សួលលែងចេញស្តី លែងនិយាយអ្វីទាំងអស់ ព្រោះនាងដឹងថា សូម្បីតែមនុស្សដែលស្រលាញ់នាងបំផុតក៏មិនអភ័យទោសឲ្យនាងផង តើអ្នកដទៃគេម៉េចនឹងយល់ចិត្តនាងទៅ?

ឃើញនាងលែងចេញស្តី នាយអង្គរក្សក៏ងាកមុខចេញទៅម្ខាងទាំងមិនស្រណុកចិត្តដែរ។ គេសម្លឹងវាលស្មៅដែលរត់ថយក្រោយឃឹតៗសែនឃឹតដោយកម្លាំងរទេះសេះ ប្រៀបបានទៅនឹងចង្វាក់បេះដូងដែលលោតយ៉ាងតឹងដោយភាពស្មុគស្មាញ។ គេគិតម្នាក់ឯងក្នុងចិត្ត៖

"កេតឌីម៉ា! យើងនាំនាងមកដោយសារតែយើងមិនអស់ចិត្ត! តែមិនមែនបានន័យថាយើងចិត្តទន់ចំពោះនាងទេ! បើនាងបន្តធ្វើអីផ្តេសផ្តាស យើងនឹងប្រដៅនាងក៏មិនទាន់ឃឹតពេលដែរ!"

ភាគទី៤៤

ក្បួនរទេះសេះដឹកនាំអភិជនខ្មែរ និងអ្នកហែហមមកដល់មាត់បឹងឡាឡាក់ LaLac ដែលពុះជ្រែកបែងចែកកោះស្មៅលឿងឲ្យទៅជាពីរផ្នែក។ ទោះបីអាកាសធាតុត្រជាក់សឹងរណ្តំថ្គាម ប៉ុន្តែផ្កាព្រៃច្រើនប្រភេទមានតូចមានធំដែលសុទ្ធសឹងតែមានពណ៌លឿងស្រស់ ដណ្តើមគ្នារីករហង់កំដរដែនដីនេះសក្តិសមណាស់នឹងឈ្មោះរបស់កោះ។

ក្រុមអ្នកធ្វើដំណើរបង្អង់ឈប់ដោយសាររទេះរបស់រាមនរិន្ទដែលនាំមុខបានឈប់សំចត។ ពីក្នុងជំនិះ ធីតាយើងសម្លឹងឃើញប្រុសស្នេហ៍បោះជំហានឃឹតៗទៅឈរមាត់បឹងស្រូបយកខ្យល់អាកាសដោយមិនមានចេញស្តី ឬងាកមកសម្លឹងអ្នកណាទាំងអស់។

មើលដំណើរគេពីក្រោយក៏ដឹងហើយថាគេកំពុងស្ថិតក្នុងស្ថានភាពតឹងតែង។ ណាមួយខ្មាសកូនចៅណាមួយខូចចិត្ត ហើយផ្លូវខាងមុខក៏មិនដឹងនឹងជួបរឿងអីខ្លះ។ នាងលើកដៃជូតទឹកភ្នែក ហើយឈានបម្រុងចុះពីរទេះ ប៉ុន្តែសំឡេងអង្គរក្សរឿនបន្លឺមកតិចៗ៖

-មិនបាច់ទៅទេ! អ្នកប្រុសខឹងប៉ុណ្ណេះហើយ គាត់មិននិយាយមិនស្តាប់អីទាំងអស់!

នារីងាកមុខសម្លឹងអង្គរក្សជំនិតដែលមុននេះបានដៀលត្មះនាង។ នាងមិនត្រឹមមិនខឹងនាយ ថែមទាំងមានអារម្មណ៍ថានាងមានមិត្តម្នាក់ដែលនៅព្រមជឿនាងទោះគេមិននិយាយចេញនូវគំនិតពិតមកក្តី។ នាងសម្លឹងភ្នែកគេចំដើម្បីឲ្យគេជឿជាក់ ហើយនិយាយតបភ្លាមៈ

-រឿន! ថៅកែKenនោះត្រូវថ្នាំសណ្តំរបស់គេ តឡូវធ្លាក់ក្នុងដៃគេ! ពួកហ្នឹងគ្មានតន្ទប្បដិមាទេ វាប្រហែលជាពាក់ព័ន្ធនឹងក្រុមចាប់ជំរិតច្រើនជាង! លោកត្រូវឃាត់លោកប្រុសរាមឲ្យបាន! ទីនេះជាទឹកដីដែលគេកាន់កាប់ បើយើងចូលដល់កន្លែងគេហើយ ពិបាកគេចផុតបានណាស់!

អង្គរក្សរឿនវេភ្នែកគិតដូចតែរាល់ដង។ ជាទូទៅគឺនាយជឿ៥0% ថាកេតឌីម៉ាអាចនឹងមិនធ្វើបាបរាមនរិន្ទទេ ប៉ុន្តែ៥0%ទៀត គេក៏ដូចគ្រប់គ្នាដែរកំពុងសង្ស័យថា ហេតុអ្វីម្តងជាពីរដងនារីនេះនៅតែព្យាយាមឃាត់ដំណើរកូនប្រុសអ្នកនយោបាយ?

គេងាកមកសួរនាងដែលកំពុងបើកភ្នែកមូលក្លំចាំចម្លើយៈ

-នាងដឹងពីណាមក?

ហាក់ទីទើរព្រោះនាងមិនចង់រំលឹកពីលំអង ប៉ុន្តែលើកនេះបើមិននិយាយក៏មិនបាន នាងតបមួយៈ

-ពេលខ្ញុំបកទៅកប៉ាល់! ខ្ញុំជួបលំអង!

អង្គរក្សរឿនចងចិញ្ចើម គេមិនសប្បាយចិត្តកាន់តែខ្លាំងនៅពេលឮពីនារីមានល្បិចនោះ ប៉ុន្តែគេនៅអត់ធ្មត់ស្តាប់កេតឌីម៉ាឧទានបន្តៈ

-លំអងរត់ចេញមករួច តែថៅកែ Kenនៅជាប់នៅទីនោះនៅឡើយព្រោះត្រូវថ្នាំគេ!

នាយរឿនធ្វើមុខហួសចិត្តៈ

-ស្រីពុតត្បុតនោះនិយាយ នាងជឿភ្លាមកេតឌីម៉ា? នាងមិនគិតថាគេមានចេតនាបង្អាក់ដំណើរយើងទេ? បើរឿងហ្នឹងអញ្ចឹងមែន ស្រីនោះមានរឿងអីចេញមករួចងាយម្លេះ?

ឌីម៉ាទីទើរ នាងចាប់រលីងរលោងទឹកភ្នែក ហើយនិយាយដោយរអាក់រអួលៈ

-ទោះពិត ឬមិនពិត ដឹងហើយយើងត្រូវគិតសិនដែរ! ចុះបើពិតមែន តើលោកថែរក្សាថៅហ្វាយលោកបានដោយវិធីណា?

នាយរឿនសម្លឹងមុខនាង រួចបែរខ្លួនឈានចុះពីរទេះសេះ។ នារីក៏ចុះដើបន្ទាប់ពីគេដែរ។ នាងដើរត ត្រុកកាត់ពីមុខក្រុមកងការពារដែលចែកទឹក និងចំណីគ្នាហូបដោយស្ងាត់ស្ងៀម ប៉ុន្តែគ្មានអ្នកណា ងាកមករវល់នឹងនាងទេ។ ចំណែកនាងក៏មិនរវល់នឹងពួកគេដែរព្រោះគោលដៅ គឺបុរសក្នុងបេះដូង ដែលកំពុងឈរបែរខ្នងហើយនាងកំពុងដើរសំដៅទៅ ទោះជាទើបតែត្រូវនាយអង្គរក្សនិយាយហាម មុននេះក៏ដោយ។

ដោយសារនាយរឿនដើរទៅដល់មុនទើបរាមនរិន្ទងាកមករកគេ ប៉ុន្តែទន្ទឹមនឹងក្រសែភ្នែកក្រឡេក ប៉ះនារីដែលឈានមកតាមពីក្រោយនាយអង្គរក្ស រាមនរិន្ទទៅជាមួហ្មង គេចងចិញ្ចើមព្រោះមិនគិត ថានាយរឿននាំនាងមកតាមដែរនោះទេ។

គេងាកមុខដើរគេចចេញ ប៉ុន្តែធីតាយើងនៅតែដើរទៅតាម។ អង្គរក្សរឿននៅឈរស្ងៀមដកដង្ហើម ធំតាមសម្លឹងកាយវិការអ្នកទាំងពីរដោយលែងចូលទៅជិតហាក់ចង់បង្កឱកាសចុងក្រោយឲ្យស្រី បង្ហាញម៉ូត ដោយសារនាយជំនិតមិនជឿទេថា រាមនរិន្ទមិនអាចយកឈ្នះពាណិជ្ជករដែកថែបក្នុង ការដណ្តើមបានបេះដូងនាង។

កេតឌីម៉ាដ៏មានៈប្រឹងលូកដៃទៅតោងហត្ថាបុរសដែលកាលពីទាបភ្លឺមុននេះបានពោលសន្យា ជាមួយនាង នូវពាក្យពេចន៍ជាច្រើនលើដងទន្លេម៉េមប៊ីរ៉ាម៉ូ។

ប៉ុន្តែទោះបីត្រូវនាងតោងដៃហើយក៏ចិត្តគេមិនមានទន់ងាកមករកនាងដែរ។

នៅពេលដែលបុរសម្នាក់លង់ស្នេហ៍លើនារីណាមួយ គេអាចអភ័យទោសឲ្យនាងគ្រប់យ៉ាង ដោយ ឡែកមានតែម្យ៉ាងប៉ុណ្ណោះ ដែលពិបាកឲ្យគេបំភ្លេចនោះគឺការក្បត់ចិត្ត។ សម្រាប់រាមនរិន្ទអតីត កាលរបស់កេតឌីម៉ាមិនបានធ្វើឲ្យអ្នកក្រោធខឹងទេ ប៉ុន្តែកាលដែលនាងបាត់ខ្លួនភ្លាមៗ ហើយ បង្ហាញមុខមកវិញដោយឃាត់ដំណើរអ្នកមិនឲ្យទៅជួបបុរសកុលសម្ព័ន្ធទើបជារឿងធំ ព្រោះនាយ យល់ថា នាងមកនៅជាមួយខ្លួនយូរម្លឹងហើយ ក្តីស្រលាញ់បែបណាក៏ខ្លួនប្រគល់ឲ្យនាងអស់ហើយ ដែរ ហេតុអីក៏នាងនៅតែចង់ខាឃាំងនាយក្នុងការទៅរកឥន្ទប្បដិមាដើម្បីទុកឱកាសឲ្យអតីតសង្សារ នាង?

គេនិយាយតិចៗដោយមិនសម្លឹងមុខនាង៖

-ចេញទៅរកវាទៅ បើមិនចង់ពិបាកខ្លួន!

ស្រីស្អាតរំភើបណាស់ដែលគេព្រមនិយាយ ព្រោះថាមុននេះនាយអង្គរក្សខ្ពស់ស្រាវបានទាយរួច ហើយថាគេនឹងមិននិយាយមិនស្ដាប់អ្វីទាំងអស់។ នាងប្រញាប់បដិសេធនឹងគេភ្លាម៖

-អត់ទេ! អូនអត់ទៅណាទាំងអស់! អូននៅជាមួយបង!

រាមនរិន្ទញញឹមប៉ុន្តែជាស្នាមញញឹមឈឺចាប់ គេងាកមកចំពីមុខនាង ហើយសម្លឹងនាងដោយពន្លឺភ្នែកមមីតែពេញដោយទោសៈ។ នាងឃើញពន្លឺភ្នែកគេក៏ប្រែទឹកមុខព្រោះនាងមិនដែលឃើញគេក្នុងស្ថានភាពសោះអង្គើយដូចគ្មានបេះដូងដូច្នេះពីមុនមកទេ រួមទាំងល្បិចមួយដែលគេចាប់រំលោភនាងព្រោះជឿសម្ដីលំអងក្ដី។ នាងរបូតក្រមាមដៃខ្សាកពីហត្ថាគេ ព្រោះតែភាពញ័ររន្ធត់។ បុរសស្រអែមចាប់ទាញដៃស្ដាំនាងឡើងដោយកម្លាំងទ្រគោះបោះបោក ព្រមទាំងបង្ហើរសម្ដីសង្កត់ពាក្យម៉ាត់ៗ៖

-កុំស្មានថាខ្ញុំមិនហ៊ានធ្វើអីនាងកេតឌីម៉ា!

អ្នកគ្រូវ័យក្មេងដក់ជលនេត្រពេញរង្វង់នេត្រា តែនាងនៅតែបន្តសម្លឹងភ្នែកគេ ព្រោះថាគេកាន់តែយល់ខុស នាងក៏កាន់តែស្រលាញ់គេ ហើយតូចចិត្ត។

នាងនិយាយទាំងតឹងណែនទ្រូងស្ទើរហោរមិនចេញ៖

-បងសម្លាប់អូនក៏ដោយ! អូន...អត់ទៅណា....ទាំងអស់!

បុរសខាំមាត់ ព្រោះគ្រឺតនឹងភាពចចេសរបស់នាង។ គេគិតថានាងក្បត់គេហើយ ក៏មិនសារភាព។ នាងជាស្រីមានល្បិចមួយរយជំពូកលាក់ក្នុងស្រោមស្លូតបូតបញ្ឆោតភ្នែកគេឯងបានយ៉ាងល្អ។ ដោយសារស្រលាញ់នាង កាំបិតក៏ធ្លាប់ត្រូវនាងចាក់ គ្រាប់សំណក៏ធ្លាប់រងជំនួសនាងដំបៅនៅឈឺមិនទាន់សះផង។ លុះដល់ដំណាក់កាលនេះហើយ នៅចង់ប្រើប្រាស់ចិត្តស្រលាញ់របស់អ្នកដើម្បីមករារាំងការងារស្វែងរកតន្ទប្បដិមាឲ្យខាងតែបានទៀត? ប្រសិនបើនាយBirdមិនភ្ញាក់រលឹកហើយរាយការណ៍ទាន់ពេល ខ្លួនមុខតែក្លាយជាប្រុសស្លាប់ក្រោមកន្ទុយក្បិនដែលទីបំផុតបរាជ័យគ្រប់យ៉ាងព្រោះតែចាញ់បញ្ឆោតនាង។

នរៈអភិជនបន្ថែមកម្លាំងរឹតដៃនាងហើយលើកឡើងខ្ពស់ជាងមុនមកទល់នឹងមុខនាយ។ គេនិយាយតិចៗទាំងខាំមាត់៖

-ចង់ស្លាប់អ្ហែស?...បានតើ! រើសទៅ! ស្លាប់នៅទីនេះ ឬមួយទៅស្លាប់នៅចំពោះមុខអាប្រុសសហាយនោះ?

ដោយការឈឺចាប់ហួសថ្លែងទាំងផ្លូវកាយ និងផ្លូវចិត្ត ឪម៉ាលែងចេញស្តី នាងគិតពីសម្លឹងមុខគេហើយយំសស្រាក់។ រាមនរិន្ទសម្លឹងទៅផ្ទៃមុខដែលធ្លាប់តែធ្វើឲ្យអ្នករំភើបចិត្ត ហើយក៏ជាផ្ទៃមុខដែលអ្នកបានចំណាំទុកយ៉ាងជ្រៅក្នុងបេះដូង ដែលឥឡូវនេះក៏កំពុងធ្វើឲ្យអ្នកឈឺចាប់។

នរៈរលាស់ដៃនាងចោលរួចសម្លឹងនាងដោយពន្លឺភ្នែកត្រជាក់ស្រឹបគ្មានមនោសញ្ចេតនា។ ទោះបីគេលែងនិយាយស្តីអ្វីពិតមែន ប៉ុន្តែពន្លឺភ្នែកគេហាក់ចង់បញ្ជាក់ប្រាប់នាងថា ទោះនាងយំដល់ជន់លិចកោះនេះទាំងមូលទៀត ក៏គ្មានផ្លូវអាចធ្វើឲ្យរាមនរិន្ទទន់ចិត្តវិញឡើយ។

ប៉ុន្តែនារីនៅតែជម្នះទុក្ខសោក ហើយបន្លឺសូរស័ព្ទអណ្តឺតអណ្តកតបទៅកាន់ពន្លឺភ្នែកគ្មានមេត្តារបស់គេ៖

-បើបងចង់សម្លាប់អូន! បងកាប់អូនបីកំណាត់ ហើយដាក់ទៅក្នុងកេសឈើ បណ្តែតចោលលើទន្លេម៉េមប៊ីរ៉ាម៉ូ ....

នាងបង្អង់ឃ្លាព្រោះនិយាយលែងចេញ គិតពីយំគគ្រូក។ នាងប្រឹងណាស់ទើបអាចបញ្ចប់ប្រយោគសោកសង្រេងនេះ៖

-គឺធ្វើឲ្យដូចបុរសអ្នកជំនួញនៅក្រុងបាដាដ ដែលបានកាប់ប្រពន្ធមានជំងឺរបស់គាត់ ដោយសារតែបាត់ផ្លែប៉ោមមួយផ្លែនោះដែរទៅ!

រឿងនិទាន "ផ្លែប៉ោមបីផ្លែ" ដែលស្តាប់រួមគ្នានារាត្រីសោយសុខនៅភូមិភូវិខានអណ្តែតមកវិញក្នុងកែវភ្នែកអភិជនខូចចិត្ត។

ពេលនេះអ្នកយល់ច្បាស់ហើយថាទំហំនៃការឈឺចាប់របស់បុរសជំនួញមានកម្រិតណា នៅពេលត្រូវគេប្រាប់ថាភរិយាខ្លួនមានប្រុសថ្មី ដែលជាទាសករស្បែកខ្មៅគួរឲ្យអាម៉ាស់។ ហេតុតែស្រលាញ់និងប្រចណ្ឌដោយងងឹតងងល់ បុរសដែលប្រើពេល៦ថ្ងៃលើខ្នងសេះដើម្បីតែស្វែងរកផ្លែប៉ោមបីផ្លែមកឲ្យភរិយាកម្សត់ ដាច់ចិត្តលើកដាវកាប់នាងជាកង់ហើយញាត់ទៅក្នុងហិបឈើបណ្តែតចោលទៅលើខ្សែទឹកទន្លេ។ គេសួរខ្លួនឯងដោយមិនដកភ្នែកពីវង់ភក្ត្រសោការបស់នាង៖

"ឬមួយយើងកំពុងឆ្កួតវង្វេងនឹងភ្លើងប្រចណ្ឌដូចបុរសអ្នកជំនួញនោះ"?

វាចាខ្សឹកខ្សួលរបស់នារីបង្ហាញម្ជូដលាន់ឡើងសាជាថ្មី៖

-មនុស្សស្រលាញ់គ្នា ត្រូវទុកចិត្តគ្នា! មែនអត់?

មិនដឹងថាបុរសអភិជនដែលឈឺចាប់ពន់ពេកចំពោះអតីតកាល ក្រោយពេលឮពាក្យមួយឃ្លានេះ គេអាចនឹកឃើញដល់សម្ដីខ្លួនឯង ដែលជាអ្នកប្រើពាក្យនេះញឹកញយដែរឬយ៉ាងណាទេ ប៉ុន្តែពន្លឺភ្នែកគេប្រែប្រួល ហើយបន្ទាប់មកគេរេវាសម្លឹងទៅទីផ្សេង។

ធីតាដែលអស់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត បន្តវាចាស្រាលៗស្ទើរមិនចង់ចេញព្រោះតែនាងកំពុងយំ៖

-តែអូនស្ដាយណាស់ ព្រោះមិនបានធ្វើសត្វត្រចៀកកាំជាមួយបង! អូនចង់ហើរទៅជុំវិញផែនដីនេះតែពីរនាក់បង !

វាមនរិទ្ធរេសរសៃចក្ខុមកសម្លឹងនាង។ ទោះយ៉ាងណា គេនៅតែចង់ដឹងថានាងនិយាយចេញពីចិត្តឬមួយជាស្នើលបោកបញ្ឆោតដ៏ជំនាញមួយ? តែផ្ទៃមុខស្រស់សង្ហាដែលត្រូវខ្មៅចខ្មាំដោយការខូចចិត្តគ្មានសញ្ញាថាគេរីករាយឡើយ។ នារីព្រិចភ្នែកដែលព្រិលដោយដំណក់ទឹក ប៉ុន្តែនាងនៅតែសម្លឹងគេព្រោះនៅតែសង្ឃឹមថាសេចក្ដីសន្ដោស យោគយល់ និងអភ័យទោសរបស់គេជារាងរហូតមកនឹងនៅតែលេចឡើងសាជាថ្មីសម្រាប់នាង ក្នុងពេលដែលភាគីបុរសក៏មិនអាចដកភ្នែកគេចេញវិញដែរដោយបន្តរេសម្លឹងតបមកគ្រាប់ភ្នែកទាំងពីររបស់នាង ម្ដងហើយម្ដងទៀត។

នៅគ្រានេះកេតឌីម៉ាប្រាកដចិត្តថាស្នេហារបស់គេដែលមានចំពោះនាងនៅតែបង្ហាញចេញមកតាមរយៈពន្លឺភ្នែកនោះ ទោះបីជាការខូចចិត្តមិនអាចឲ្យគេញញឹមបាន ប៉ុន្តែនាងខ្លួនឯងខំញញឹមទាំងទឹកភ្នែកទៅរកបុរសម្ចាស់ចិត្ត ។

នាងទម្លាក់ភ្នែកសំដៅទៅរកហត្ថាបុរសដែលកន្លងមកមិនដែលនឿយណាយក្នុងការឱបក្រសោបរាងកាយនាង ពេលនេះបែរជានៅធ្មឹងព្រោះតែរបាំងអតីតកាលមួយដែលពិបាកឲ្យគេធ្វើពើជាមិនដឹងមិនឮ និងពិបាកឲ្យគេកុហកចិត្តខ្លួនឯង។ កេតឌីម៉ាងើបមុខសន្សឹមៗសម្លឹងបបូរមាត់ក្រៀមក្រោះដែលពេលណាក៏នៅតែស្រស់សង្ហា និងមានអំណាច។ នាងឃើញគេនៅតែសម្លឹងនាងព្រោះនាងដឹងថារឿងនិទានសត្វត្រចៀកកាំ និងបុរសអ្នកជំនួញជាមួយផ្លែប៉ោមបីផ្លែ កំពុងធ្វើឲ្យគេច្របូកច្របល់ចិត្ត ដោយសារអនុស្សាវរីយ៍ល្អៗទាំងអស់ស្រាប់តែនៅសុខៗត្រូវចូលមកលាយឡំជាមួយរូបភាពពាណិជ្ជករដែកថែបដែលគ្មានតម្លៃ។

នាងចង់ជួយគេឲ្យចាកចេញពីទុក្ខព្រួយនេះ ហើយឲ្យគេប្រាកដថានាងមានតែគេម្នាក់ជារៀងរហូតទើបស្រីស្រស់ឈានទៅឱបក្រសោបរាងកាយបុរសសង្ហាកណ្ដាលធម្មជាតិស្រស់ត្រកាលនៃវាលស្មៅលាយបុប្ផាព្រៃពណ៌លឿងក្រោមលំហមេឃស្រទំ។

បុរសមិនបានឱបនាងតបតែគេក៏មិនងាកចេញដែរ។ គេនៅទ្រឹងក្នុងរង្វង់ដៃនាង គឺនៅរវាងសេចក្ដីស្នេហា និងការឈឺចាប់។ គេគិតម្នាក់ឯងទាំងទឹកភ្នែកស្រក់ក្នុងបេះដូង។

"កេតឌីម៉ា! នៅជាមួយអូនមិនទាន់បានប៉ុន្មានផង បងស្រលាញ់អូនដល់ថ្នាក់នេះ? ស្រលាញ់ដល់ថ្នាក់អូនធ្វើអ្វីក៏គេអាចមានហេតុផលជានិច្ចក្នុងចិត្តបង? សូម្បីរឿងនិទានប៉ុន្មានម៉ាត់អាចធ្វើឲ្យបងភ្លេចការឈឺចាប់ទាំងអស់វិញបានភ្លាមៗ។ បើបងមិនមែនជារាមនរិន្ទដែលមានការធំជាប់ប្រាណ មិនមានកូនចៅឆ្វេងស្ដាំតាមសម្គាល់ឬក បងមុខតែមិនខ្វល់ទេថា ទោះអូនអាក្រក់ ទោះអូនក្បត់បង ក៏បងនៅតែចចេសនៅជាមួយអូន!"។

គេឈ្ងោកសម្លឹងសក់រលើបខ្មៅរបស់ស្រីស្អាតដែលនៅក្បែរទ្រូងទន្ទឹមនឹងពេលសំឡេងមួយលាន់មកពីចម្ងាយ៖

-ពួកយើងមើលហ្នក់! លោករ៉ាទូទេតើ!

រាមនរិន្ទងើបមុខទៅរកប្រភពនៃសូរសំឡេង។ អ្នកឃើញនាយគង់ចង្អុលទៅកាន់មាត់បឹង ដែលនៅទីនោះទូកដមួយកំពុងរំកិលចូលមកដល់។ កាន់តែគួរឲ្យភ្ញាក់ផ្អើលគឺនៅក្បាលទូកបុរសម្នាក់ផាត់កន្ទុកទាបកន្ដាល់កំពុងឈរជ្រែង និងញញឹមមក។ កូនប្រុសអ្នកនយោបាយលាន់មាត់តិចៗ៖

-លោករ៉ាទូ?

ធីតាបង្ហាញម៉ូតងើបមុខចេញពីទ្រូងហើយរាមនរិន្ទបានទាញរង្វង់ដៃនាងចេញពីចង្កេះគេក្នុងពេលតំណាលគ្នានោះ។ នារីដឹងថា សភាពការណ៍កាន់តែហួសពេលក្នុងការហាមឃាត់គេ ម្ល៉ោះហើយនាងនិយាយតិចៗទៅកាន់គេភ្លាមមុនពេលគេទៅឆ្ងាយជាងនេះ៖

-ប្រយ័ត្នខ្លួនផង! ពួកគេដាក់ថ្នាំសណ្ដំឲ្យចៅកែKenនិងលំអង! តានោះមានល្បិចច្រើនណាស់!

បុរសងាកមកសម្លឹងនាង។ ក្រសែភ្នែកគេហាក់ចង់បញ្ជាក់ថា សម្ដីចុងក្រោយរបស់នាងពិត ឬក្លែងក្លាយ ប៉ុន្តែគេមិនហើបមាត់សួរនាងទេ។ តរុណីក៏មិនចេញស្ដីដូចគ្នា ប៉ុន្តែភាពភ័យបារម្ភ និងឈឺឆ្អាលអណ្ដែតចេញពីក្រសែភ្នែកនាងដែលកំពុងសម្លឹងគេនោះ ធ្វើឲ្យនាយអភិជនត្រូវតែកាត់ចិត្តបែរខ្លួនបោះជំហានចេញ គេចពីមនោសញ្ចេតនាទន់ជ្រាយរបស់ខ្លួន។

នៅពេលទូករំកិលចូលមកជិតដល់ក្បូនរទេះសេះដែលសំចតចាំហើយ បុរសទាបកន្ដាល់ឱនក្បាលស្វាគមន៍ភ្ញៀវតាមរបៀបអ្នកកុលសម្ព័ន្ធនោះ អង្គរក្សរឿនដើរតម្រង់មករកកេតឌីម៉ាដោយមាន

កញ្ចប់មួយក្នុងដៃ។ គេហុចឲ្យនាងហើយមិនមានចេញស្តីអ្វីទេ ដោយបែរត្រឡប់ទៅឈរក្បែរ ថៅហ្វាយប្រុសដែលកំពុងត្រូវបានស្វាគមន៍ដោយក្រុមកុលសម្ព័ន្ធទើបនឹងឆ្លងទឹកមកដល់។

ឌីម៉ាឱនស្រាយកញ្ចប់នោះមកមើល នាងដឹងថានោះជាសម្លៀកបំពាក់នារីមូស្លីមដែលនាយគង់ទិញ បានកាលពីព្រឹក។ ក្នុងគ្រាប្រថុចញ៉ុច នាងបានត្រឹមរើយកកន្សែងHijab មកទទូរបិទបាំងសក់តែ ប៉ុណ្ណោះ។ នាងដឹងថាអង្គរក្សរឿនកំពុងយកចិត្តទុកដាក់នឹងសុវត្ថិភាពនាងដែរ បានន័យថា គេក៏ កំពុងមិនទុកចិត្តពួកកុលសម្ព័ន្ធនេះដូចគ្នា។

-សូមស្វាគមន៍ៗ!

សំឡេងលោកវ៉ាទូនៅតែលាន់មកក្រអៅក្រអឹតដូចនៅឯពិធីជេញថ្លៃនៅ JayaPuraដូច្នោះដែរ។ ហើយទីបំផុត មនុស្សទាំងអស់ត្រូវបានគេអញ្ជើញឡើងទូកឆ្លងទៅកាន់ត្រើយម្ខាងក្រោមភាពភ័យ ព្រួយរបស់កេតឌីម៉ា។

## វគ្គទី២០

## រាជិនីនៃកុលសម្ព័ន្ធ អាសាដ

កុលសម្ព័ន្ធអាសាដរស់នៅរាយប៉ាយតាមតំបន់ព្រៃក្បែរជ្រលងភ្នំ និងមាត់បឹងដែលសម្បូរទៅដោយ ដើមត្រែងពណ៌លឿងក្រមៅ។

ក្រុមមនុស្សដែលហែហមកូនប្រុសអ្នកនយោបាយមកពីកម្ពុជាត្រូវបានបុរសឈ្មោះវ៉ាទូនាំដំណើរ ឆ្លងបឹង និងជិះរទេះសេះបន្តកាត់តាមវាលស្មៅ និងវាលស្រែច្រើនដំណាក់ទៀត ទម្រាំពួកគេអាច ចូលមកដល់ភូមិ**កុលសម្ព័ន្ធ អាសាដ**នៅចំពេលថ្ងៃរៀបលិច។

ភូមិរបស់ពួកគេនៅបន្តគ្នារដឹកព័ទ្ធជុំវិញដោយចម្ការOliveនិងរុក្ខជាតិ Jujube (ផ្លែម្យ៉ាងស្រដៀង ពុទ្រា)។ ចម្ការនីមួយៗក្រាលលំអដោយវាលស្មៅត្រឹមស្អាតដូចគេក្រី។ ភាពស្រស់បំព្រងនៅទីនេះ បង្ហាញចេញនូវកិត្យានុភាព និងភាពសុខដុមរមនាសម្បូរសប្បាយជាងកាលពីនៅភូមិភូរីខាន់ទៅ ទៀត។ ក្នុងភូមិនោះទៀតសោតភាគច្រើនជាកូនផ្ទះឈើប្រក់ស្លឹកមានរាងមូលខ្លះ ទ្រវែងខ្លះ តែ ត្រង់ជួរល្អគួរជាទីគយគន់។ អ្វីដែលចម្លែក គឺគេកម្រឃើញមានមនុស្សម្នាបង្ហាញខ្លួនណាស់ បើមាន ក៏យូរម្តងៗក្នុងសម្លៀកបំពាក់បិទបាំងអស់ទាំងខ្លួន ពិសេសនារីៗមានតែក្រឡង់ភ្នែកប៉ុណ្ណោះដែល អ្នកដំណើរអាចមើលឃើញ។ រីតតែសំខាន់ គឺម្នាក់ៗពេលឃើញលោកវ៉ាទូ បាននាំគ្នាលំឱនកាយ

គោរពដូចជាវត្ថុសក្ការៈ ធ្វើឲ្យជនចំណូលថ្មីទាំងអស់ដឹងថាបុរសនេះជាមនុស្សមានយសស័ក្តិរបស់កុលសម្ព័ន្ធ**អាសាដ**ប្រាកដណាស់។

ពួកគេត្រូវបានជូនដំណើរមកដល់ផ្ទះឈើធំខ្ពស់ស្អាតខុសពីគេមួយ។ នៅពីមុខស្លាកធ្វើពីឈើខ្មៅ និងលំអដោយក្បាច់ភ្លុកដំរីជារាងស្នែង គេឃើញមានអក្សរមួយជួរត្រង់ភ្លឹងដែលសរសេរពណ៌ស្ពាន់ ប៉ុន្តែមិនមានភ្ញៀវណាម្នាក់ មើលយល់ទេព្រោះជាអក្សរបែបអារ៉ាប។

**ភាគទី៤៥**

លោករ៉ាទូញញឹមមកកាន់ភ្ញៀវដែលកំពុងនាំគ្នាមើលស្លាកនោះព្រោះមិនអាចអានបាន ប៉ុន្តែរចនាបថនិងសាច់ភ្លុកសថ្លាឆ្ងង់បានទាក់ទាញអារម្មណ៍ពួកគេ។ ជនទាបកន្ទាល់លួចដៀងភ្នែកមើលបុរសអភិជនខ្មែរដែលកំពុងនៅឈរឆ្ងាយពីគេដោយទឹកមុខស្រងូត។ បុរសនោះលួចញញឹមមុនពេលបែរទៅគោះទ្វារតិចៗ ភ្លេចគិតថាគ្រប់កាយវិការ និងទឹកមុខចម្លែកគួរឲ្យសង្ស័យរបស់គាត់កំពុងស្ថិតក្នុងក្រសែភ្នែកកេតឌីម៉ា។ សម្ដីលំអងកាលពីព្រឹកលាន់ឮមកសាជាថ្មីក្នុងសោតាទាំងគូហាក់ដូចជានៅថ្មីៗ៖

"យើងទៅរកតាមរ៉ាទូហ្នឹងដល់ភូមិវាទាំងព្រលប់ វាថាឲ្យយើងចូលសម្រាកសិន នឹងអាលយករបស់មកនិយាយលក់ដូរ ប៉ុន្តែដឹងអីគឺវាដាក់ថ្នាំក្នុងស្រាឲ្យយើងផឹក! ខ្ញុំសំណាងមិនបានផឹករបស់ហ្នឹងបានជាកណ្ដាលយប់ ខ្ញុំលួចចេញមកបាន! គ្នារត់តាមជើងភ្នំពិបាកណាស់ទម្រាំបានមកដល់កំពង់ចម្លងនេះ"។

នារីដកភ្នែកចេញពីបុរសនោះ រួចសម្លឹងទៅប្រុសស្នេហ៍ដែលនៅឈរស្ងៀមស្ងាត់ឆ្ងាយពីអ្នកផង។ នាងបន់ក្នុងពោះថាកុំឲ្យមានហេតុការណ៍អកុសលណាមួយកើតមានឡើងចំពោះគេទៅចុះ បើមិនដូច្នោះទេ ទោះប្ដូរជីវិតនាង និងការពារគេចេញពីកន្លែងនេះ។

ត្រឹមតែមួយដង្ហើមប៉ុណ្ណោះ ទ្វារក៏របើកឡើងដូចមានគេត្រៀមចាំនៅទីនោះជាស្រេចអញ្ចឹង។ ឌីម៉ាងាកសម្លឹងទៅរកអ្នកបើកទ្វារ។ នោះជាស្ត្រីចំណាស់ដែលផ្ទៃមុខសដូចក្រណាត់ទេសឯក។ ទោះបីគាត់រុំសក់តែបង្ហាញប្រឡោះមុខខុសពីនារីផ្សេងៗ ប៉ុន្តែគាត់មិនហ៊ានហារស្តីអ្វីទាំងអស់បានត្រឹមតែឱនលំទោនមកកាន់លោករ៉ាទូ និងភ្ញៀវហើយធ្វើកាយវិការអញ្ជើញពួកគេចូលទៅក្នុងផ្ទះ។

ស្ត្រីនោះនាំពួកគេដើរកាត់តាមសួនផ្ការយោលចម្រុះពណ៌គួរឲ្យត្រេកត្រអាល។ នៅចំហៀងម្ខាងជាជម្រាលចុះទៅកាន់មាត់បឹងពណ៌បៃតងខ្ចីដោយកម្រាលស្មៅហាក់បីដូចជាមានអ្នកថែទាំសំអិត

សំអាង ត្រូវនឹងពន្លឺថ្ងៃចុងក្រោយនារសៀលជ្រាលជ្រេព្រមទាំងស្រទាប់ផ្សែងពណ៌ប្រផេះ គ្មានអ្នកណាម្នាក់មិនគិតថាទិដ្ឋភាពនៅទីនេះជាស្ថានសួគ៌លើផែនដីទេ។

ចំណែកគេហដ្ឋានដែលលេចអណ្ដែតពីកណ្ដាលចំណោមទេសភាពប្រៀបនឹងស្ថានត្រៃត្រិង្សនោះ គឺជាប្រភេទផ្ទះឈើដែលមានរាងខ្ពស់ស្រលះ ប៉ុន្តែមានក្បូរក្បាច់រចនាស្រដៀងគ្នាទៅនឹងរាជវាំងនៃប្រទេសឡាវ ខុសត្រង់ថាតែមិនមានរចនាពណ៌មាសឆើតឆាយតែប៉ុណ្ណោះ។

ផ្ទះនោះមានជណ្ដើរប្រកបដោយក្បូរក្បាច់ស្ថិតនៅចំពីមុខផ្ទះត្រង់ឡើងទៅលើគ្មានលាក់ស្នាមបត់ ឬកាច់កុងអ្វីដូចផ្ទះឈើដទៃក្នុងតំបន់អាស៊ីអាគ្នេយ៍ឡើយ។

"ពួកគេនៅដល់ចុងកាត់មាត់ញកម្លឹងៗ ហេតុអ្វីក៏អាចរកបានជាងពូកែចំណាន ហើយរៀបចំផ្ទះសម្បែងបានប្រណិតថ្នាក់នេះ?"រាមនរិន្ទលួចគិតក្នុងចិត្តដោយសម្លឹងទៅសំពត់សូត្រជាច្រើនដែលត្រូវបានរៀបតុបតែងបិទបាំងតាមថ្នាក់ជណ្ដើរ និងបង្កាន់ដៃខាងលើផ្ទះ។

លោកវ៉ាទូដើរមករករាមនរិន្ទដោយអាកប្បកិរិយាគួរសម ប៉ុន្តែសំឡេងគាត់ពោលឮៗគ្របដណ្ដប់លើបរិយាកាសស្ងប់ស្ងាត់ដោយការភ្ញាក់ផ្អើលរបស់ក្រុមអ្នកដំណើរ៖

-អេឡា អញ្ជើញថៅកែរាមឡើងទៅលើផ្ទះទាន!

បុរសសង្ហាជ្រួញចិញ្ចើមតែស្នាមញញឹមអមមកកំដរគ្នាជាសញ្ញាថាអ្នកមានអារម្មណ៍ភ្ញាក់ផ្អើល ប៉ុន្តែចូលចិត្តបដិសណ្ឋារកិច្ចនេះ។ គេងើបមុខសម្លឹងទៅលើផ្ទះដែលលេចចេញនូវស្រីៗមួយក្រុមដើរចែកជាពីរជួរស្មើគ្នាអមពីមុខជណ្ដើររង់ចាំទទួលដំណើរអ្នកប្រុសជាមួយឈុតសម្លៀកបំពាក់ពណ៌និងក្រណាត់ស្បៃគ្របមុខ និងសក់ទុកតែប្រឡោះភ្នែកធំៗខ្មៅក្រឹប។

រាមនរិន្ទមកដល់ពីមុខជណ្ដើរដោយមានអង្គរក្សរឿនស្ទុះចូលមកក្បែរក្រោមពន្លឺភ្នែកពិភាល់របស់កេតឌីម៉ាដែលលាក់មុខក្នុងកន្សែងទទូរដូចនារីមូស្លីម។ នាងចង់ចូលទៅជិតគេណាស់ ព្រោះនាងមិនទុកចិត្តបុរសទាបកន្ទុលថាមានបំណងល្អដាច់ខាត ប៉ុន្តែគេនៅកំពុងខឹងនាងនៅឡើយ។

សំឡេងបុរសនាំដំណើរលាន់មកបន្ថែម៖

-អេឡាសូមអញ្ជើញតែថៅកែរាមម្នាក់ទេ! អ្នកឯទៀតចាំនៅទីនេះសិន!

បុរសឈ្មោះរឿនបង្ហាញអាការៈមិនអស់ចិត្ត ក្នុងពេលកូនប្រុសអ្នកនយោបាយនិយាយមួយៗ៖

-អត់ទោសលោកវ៉ាទូ! ខ្ញុំនៅមិនទាន់ស្គាល់ថាអ្នកណាជា "អេឡា" ផងទេ!

បុរសធាត់ទាបឱនកាយសាជាថ្មី គាត់ស្ដីតបដោយទឹកមុខញញឹមៈ

-អេឡា ជាកូនស្រីមេកុលសម្ព័ន្ធចាស់ដែលស្លាប់ទៅ ហើយក៏ជាអ្នកមានអំណាចជាងគេនៅកុលសម្ព័ន្ធអាសាដនេះ។

រាមនរិន្ទរក្សាភាពនឹងនលើផ្ទៃមុខ ប៉ុន្តែនាយរឿនមិនអាចអត់ធ្មត់បានទេ គេពោលសួរវិញមិនបង្វែងបង្វៀងៈ

-អ្នកនៅលើផ្ទះនោះមានទាក់ទងអីនឹងរឿងឥន្ទប្បដិមា? យើងមកទិញរបស់ បើលោកបញ្ចេញរបស់មក យើងប្រគល់លុយភ្លាម ចាំបាច់អីមានក្បួរក្បាច់ច្រើន!

លោកវ៉ាទូហាក់ថ្លោះទឹកមុខនៅពេលឮសម្ដីនាយរឿន។

រាមនរិន្ទដឹងថាស្ត្រីឈ្មោះអេឡាដែលលោកវ៉ាទូនិយាយ ប្រាកដជាមានឥទ្ធិពលសំខាន់ដែលបុរសនេះមិនចង់ឲ្យមានអ្នកណាល្មើសសូម្បីតែពាក្យសម្ដីដាក់នោះទេ។ ពាក្យពេចន៍ត្រង់ធ្លូរបស់នាយអង្គរក្សមុខតែបានធ្វើឲ្យប៉ះទង្គិចអារម្មណ៍បុរសនេះច្បាស់ណាស់ ម្ល៉ោះហើយកូនប្រុសអ្នកតំណាងរាស្ត្រខំសម្រួលបរិយាកាសមកវិញៈ

-កុំនិយាយអញ្ចឹងរឿន! អេឡាផ្ដល់កិត្តិយសឲ្យយើង ជារឿងល្អមួយ! លោកវ៉ាទូ តោះយើង!

គេឈានជើងឡើងជណ្ដើរក្រោមក្រសែភ្នែកពិនិត្យពិច័យ និងពិភាល់របស់កងការពារទាំងឡាយ។ ឌីម៉ាតាមសម្លឹងជំហានមាំមួនរបស់គេហើយទប់ស្កាត់ភាពភ័យខ្លាចដែលកាន់តែមានទំហំធំឡើងៗក្នុងទ្រូង។

"សំខាន់គេពេលនេះគេទៅតែម្នាក់ឯង! អង្គរក្សម្នាក់ក៏គ្មាន មានរឿងអីយើងអាចស្ងប់ចិត្តបាន? ចំណោកអ្នកខាងលើនោះជានរណាម៉េចក៏អាថ៌កំបាំងហើយក្រអឺតក្រទមម្ល៉េះ? គេចង់ជួបភ្ញៀវតែមិនព្រមបង្ហាញមុខ សំខាន់គេស្គាល់អត្តសញ្ញាណ និងហៅឈ្មោះចំៗទៀត តើគេតាមដានពួកយើងតាំងពីពេលណាមក? ឬមួយគេជាក្រុមចាប់ជំរិតដូចដែលលំអងនិយាយកាលពីព្រឹក?"

នឹកដល់ត្រង់នេះនាងនឹកដល់អតីតសង្សារដែលឮថាបានត្រូវថ្នាំសណ្ដំហើយជាប់នៅទីនេះក្នុងដៃក្រុមកុលសម្ព័ន្ធនៅឡើយ។ តើពេលនេះគេមានវាសនាបែបណាហើយ?

ទោះបីចិត្តស្នេហារលាយសាបសូន្យក្លាយជាសាបដូចទឹកទន្លេ ប៉ុន្តែទោះយ៉ាងណាគ្រោះថ្នាក់បុរសនោះមុខតែជះឥទ្ធិពលមកលើសុវត្ថិភាពរាមនរិន្ទ។

ស្រីស្រស់ដែលលាក់មុខក្នុងកន្សែងHijabរភ្នែកឆ្វេងស្តាំសម្លឹងជុំវិញខ្លួន។ ធម្មជាតិចាប់ផ្តើមងងឹតព្រាលៗជាបណ្តើរៗ មានន័យថា រាត្រីនេះពួកគេប្រាកដជាត្រូវនៅទីនេះ ព្រោះគ្មានផ្លូវត្រឡប់ទៅកំពង់ចម្លងវិញទាន់ពេលឡើយ។

នៅខាងលើផ្ទះឈើ បុរសខ្មែរដែលហែហមដោយស្រីស្អាតពាក់របាំងមុខបានចូលមកដល់បរិវេណបន្ទប់ធំដែលជះពន្លឺពណ៌មាសដោយចង្កៀងក្រមួនសឹងថាគ្រប់ជ្រុងពាសពេញបរិវេណផ្ទះ។ ក្លិនខ្លឹមចន្ទន៍ក្រអូបឆ្ងួលមកប៉ះច្រមុះនាយ ធ្វើឲ្យនាយមានអារម្មណ៍ថាទីនេះសមជាកន្លែងរបស់មនុស្សស្រីជាជាងរបស់អ្នកមានអំណាចណាម្នាក់។

បុរសត្រូវបានអញ្ជើញឲ្យសម្រាកលើគ្រឿងសង្ហារិមពណ៌រលោងស្រិលដោយប្រភេទឈើមានតម្លៃហើយតុបតែងក្បាច់យ៉ាងវិចិត្រ។ នៅចំកណ្តាលបន្ទប់ធំនេះ ក្រុមនារីបិទមុខនាំគ្នាអង្គុយជាពីរជួរអមគ្រែឈើមួយ ប្រក់ពីលើដោយដំបូលពណ៌ស និងមានវាំងននស្បៃសស្តើងបិទបាំងជុំវិញផង។

តាមរយៈពន្លឺចង្កៀងដែលរួមគ្នាជះចិញ្ចាច រាមនរិន្ទអាចមើលដឹងថានៅលើគ្រែនោះមាននារីម្នាក់កំពុងអង្គុយមើលអ្វីម្យ៉ាងនៅលើដៃនាង។

"មិនសមថានាងកូនស្រីកុលសម្ព័ន្ធរស់នៅក្បែរជ្រលងភ្នំ ប៉ុន្តែប្រើកុំព្យូទ័រដែរទេ? "គេគិតក្នុងចិត្តម្នាក់ឯង។ ជាមួយនោះ ភាពជាបុរសបានបង្ខំចិត្តនាយឲ្យរាយមាយចង់ឃើញមុខនាង។

ភ្លាមៗនោះសំឡេងស្រួយស្រទន់របស់ម្ចាស់គ្រែអាថ៌កំបាំងលាន់ឮមក៖

-លើកទឹកផ្កាជូនភ្ញៀវ!

ទោះបីវាចាលើកដំបូងរបស់នាងពីរោះពិសាតែរាមនរិន្ទមិនអាចស្តាប់យល់នោះទេ។ គេងាកទៅឃើញនារីអាវសដែលដើរចេញមកពីក្រោយផ្ទះជាមួយនឹងផើងថ្មតូចៗលើថាសដីឥដ្ឋ។ កែវភ្នែកបុរសអភិជនរភ្នែកសម្លឹងភេសជ្ជៈក្រអូបថ្លាក្នុងផើងហើយលូកដៃទទួលវាដោយទឹកមុខប្រិមប្រិយមិនអាចឲ្យម្ចាស់ផ្ទះដឹងបានពីភាពសង្ស័យ និងងឿងឆ្ងល់ក្នុងចិត្តឡើយ។ នារីបម្រើភេសជ្ជៈថយទៅវិញបាត់ ប៉ុន្តែសំឡេងបញ្ជាអម្បាញ់មិញលាន់ឮមកវិញ៖

-សូមអញ្ជើញពិសា!

កូនផើងទឹកលើដៃកូនប្រុសអ្នកនយោបាយរាងចង់រង្គើដោយសារឥទ្ធិពលដែលអ្នកកាន់វាត្រូវភ្ញាក់ផ្អើលដោយភាសាអង់គ្លេសនារីកុលសម្ព័ន្ធ។ ទោះយ៉ាងណាគេចាំបាច់ត្រូវតែឆ្លើយវិញជាកិច្ចគួរសម

ប៉ុន្តែសម្ដីរៀបហារចេញត្រូវផ្អាកជាបន្ទាន់ដោយសារភ្នែកទាំងគូត្រូវគាំងចលនាដោយសារស្ត្រីនោះសន្សឹមៗបើកទាញវាំងននស្បៃបង្ហាញកាយ។

នារីតូចច្រឡឹងដែលគ្រងកាយដោយសម្លៀកបំពាក់ប្រពៃណីពណ៌ផ្កាឈូកខ្ចី និងគ្របក្បាលមុខមាត់ដោយក្រណាត់ស្បៃដិនជាប់ជាមួយគ្រាប់ត្បូងពណ៌មាសល្អបំព្រង បានបោះដៃជាសញ្ញាបណ្ដេញនារីផ្សេងៗឲ្យចាកចេញ ធ្វើឲ្យកន្លែងនេះនៅសល់បុរសវ៉ាទូ និងអភិជនកម្ពុជាដ៏ស្រស់សង្ហា។

ទោះបីនាងមិនបានទាញទម្លាក់ស្បៃបិទបាំងមុខនោះចេញ ប៉ុន្តែនាងអាចមានវ័យក្មេងជាងកេតឌីម៉ាទៅទៀតក្នុងក្រសែភ្នែករាមនរិទ្ធ បើយោងតាមប្រអប់ដៃសប្បត់របស់នាងដែលកំពុងរៀបចំកុំព្យូទ័រទុកមួយឡែក។

"គ្រាប់បើដល់ហើយស្រីម្នាក់នេះ! មើលទៅឈ្មោះអេឡាសមនឹងនាងណាស់!"គេគិតក្នុងចិត្ត។ ភាពត្រេកត្រអាលក្នុងភាពជាមនុស្សប្រុសកម្រើកមកវិញដោយសារការមិនអស់ចិត្តដែលមិនបានឃើញមុខនាង។ទន្ទឹមនឹងនោះដែរ គេបានកំណត់ក្នុងចិត្តរួចជាស្រេចថា នាងប្រាកដជាស្រីស្អាតម្នាក់ត្រូវការបិទបាំងសម្រស់របស់នាងតាមទម្លាប់សាសនាដែលហាមប្រាមមិនឲ្យប្រើប្រាស់សម្រស់នោះបង្កើតភាពត្រេកត្រអាលដល់ភេទផ្ទុយ។

សំឡេងនាងបន្តមកកាត់ផ្ដាច់អារម្មណ៍បុរសដែលកំពុងស្លុងក្នុងការស្មានៗ៖

-ហេតុអ្វីក៏អ្នកហ៊ានចំណាយលុយ ៥០០លានRupiahsមកដេញថ្លៃយកតន្ត្របូ្បដិមា?

តាមពិតមនុស្សមានប្រាក់ទិញរបស់ គេមិនចាំបាច់ត្រូវប្រាប់អ្នកលក់ពីមូលហេតុដែលគេចង់ចំណាយលុយទេ ប៉ុន្តែសំឡេងទន់ភ្លន់បង្កប់នូវអំណាចរឹងប៉ឹងគួរឲ្យទាក់ចិត្តរបស់ស្ត្រីក្មេងនេះធ្វើឲ្យរាមនរិទ្ធមិនដាច់ចិត្តធ្វើក្រអឺតក្រទមជាមួយនាងសោះឡើយ។ គេនិយាយតបមួយៗ៖

-របស់ល្អទាល់តែចំណាយច្រើនបន្តិច! រឿងនេះធម្មតាទេតើ!

ស្ត្រីកុលសម្ព័ន្ធងាកមកសម្លឹងមុខបុរសដែលរក្សាស្នាមញញឹមលើផ្ទៃមុខ។ បើនាងជាមនុស្សមិនមែនជាខ្មោច គឺនាងគ្មានផ្លូវគេចបានពីមន្តស្នេហ៍របស់អ្នកប្រុសកម្ពុជាឡើយ។ ដូច្នោះហើយបានជានាងវេភ្នែកគេចចេញពីនាយ រួចនិយាយក្នុងសព្ទសូរខឹងដង៖

-ដូចចង់បង្ហាញថា អ្នកមានលុយច្រើនណាស់អញ្ចឹង?

រាមនរិន្ទញាក់ស្មាជាសញ្ញាមិនយល់ស្រប គេតបជាមួយនារីចម្លែកភ្លាមៈ

-ខ្ញុំអត់បាននិយាយអញ្ចឹងទេអេឡា!

ស្រ្តីតូចច្រឡឹងហាក់អៀនខ្មាសជាខ្លាំងពេលឮបុរសហៅឈ្មោះនាងហើយសម្លឹងនាងដោយខ្សែភ្នែកមុត។ នាងកាន់តែបែរខ្នងគេចប៉ុន្តែមាត់និយាយៈ

-អ្នកចូលមកកន្លែងខ្ញុំហើយនៅមានៈទៀត! ចុះអ្នកធ្វើអីបាន បើខ្ញុំចាប់ពួកអ្នកឃុំដើម្បីទារយកប្រាក់ដែលអ្នកអួតអាងនោះ?

រាមនរិន្ទញញឹមដូចរាត្រីចុងក្រោយនៅJayaPuraដែលគេបានទទួលមនោសញ្ចេតនាតបស្នងរបស់ស្រីបង្ហាញម៉ូត។ ទឹកមុខ និងឫកពាគេធ្វើឲ្យលោកវ៉ាទូរភ្នែកលួចគិតលិបលពីរឿងអ្វីមួយ។ ប៉ុន្តែបុរសខ្មែរនៅតែនិយាយមួយៗទាំងក្រោកដើរមកពីក្រោយនារីអាថ៌កំបាំងៈ

-អ្នកនាងមិនធ្វើអញ្ចឹងទេ!

តាមប្រលោះដែលនៅសេសសល់ពីស្បែត្បូងចរណៃ ធីតានៃកុលសម្ព័ន្ធអាសាដចងចិញ្ចើម ប៉ុន្តែភាពអណ្តែតអណ្តូងលេចឡើងក្នុងពន្លឺភ្នែកនាង។ ស្រីមានអំណាចមិនបែរខ្នង តែបេះដូងនាងលោតញាប់តាមធម្មជាតិស្រីវ័យក្មេងជួបបុរសសង្ហា។ នាងនិយាយគំរោះគំរើយៈ

-អ្នកទុកចិត្តខ្លួនឯងហួសពេកហើយរាមនរិន្ទ?

លោកវ៉ាទូលួចងើបមុខមើលរាមនរិន្ទដែលឈរបង្អួតរាងកាយខ្ពស់សង្ហាខុសប្លែកពីធម្មជាតិនៃអម្បូរជនជាតិដើមអាសាដ ដែលទាំងបុរស និងនារីមានរាងទាបទ្រនាប់។ បុរសវ័យកណ្តាលមិនដឹងថាអភិជនកម្ពុជាសម្អាងអ្វីទេក្នុងការបង្ហាញជំនឿចិត្តកណ្តាលព្រៃភ្នំនេះ ប៉ុន្តែប្រហែលជានេះជាទម្លាប់នាយដែលចាប់កំណើតមកក្នុងត្រកូលគ្រួសាររុងរោចន៍ និងមានបុគ្គលិកលក្ខណៈសុទិដ្ឋិនិយម។

ប៉ុន្តែការពិតដែលរាមនរិន្ទយកមកអះអាងគឺផ្សេងពីនេះ។ អ្នកប្រុសនិយាយតបនឹងម្ចាស់ស្រីនៃគេហដ្ឋានក្បែរជ្រលងភ្នំៈ

-អត់ទេ! តែខ្ញុំដឹងថាពួកនិស្សិតមកពី Swinburne គេអត់ធ្វើរឿងខុសច្បាប់ដើម្បីប្រាក់ទេ!

នារីកុលសម្ព័ន្ធនៅទ្រឹងលែងមានប្រតិកម្ម ប៉ុន្តែធាតុពិតនាងគឺកំពុងភ្ញាក់ផ្អើល។ ធីតាតូចច្រឡឹងបែរក្រោយសម្លឹងមុខបុរសដែលញញឹមពព្រាយបង្អួតសម្រស់នៅនឹងកែវភ្នែកនាង។ នាងដៀងភ្នែក

សម្លឹងទៅផ្ទាំងរូបថតដែលព្យួរនៅជញ្ជាំងម្ខាងនៃផ្ទះឈើឃ្លាតពីគ្រែរបស់នាងប្រមាណ១០ម៉ែត្រ។ នាងទម្លាក់គ្រាប់ភ្នែកមកសម្លឹងកម្រាលក្ដារហើយនិយាយទម្លាក់សំឡេង៖

-ភ្នែកអ្នកមើលបានឆ្ងាយគួរសម!

បុរសសង្ហាដើរត្រឹកៗមកក្បែរនាង ធ្វើឲ្យស្រីក្មេងប្រញាប់គេចចេញក្រោមការតាមដានរបស់បុរសវ័យកណ្ដាលដែលគិតអ្វីមួយច្រិមច្រុមតែម្នាក់ឯង។

បុរសកម្ពុជានិយាយតិចៗពីក្រោយស្ត្រីអាថ៌កំបាំង៖

-៨ឆ្នាំហើយ! តែខ្ញុំនៅចាំនាងបានម៉េដឌី!

លោករ៉ាទូក្រឡឹងគ្រាប់ភ្នែកព្រោះភ្ញាក់ផ្អើល។ គាត់នៅឱនក្បាលធ្វើដូចមិនហ៊ានងើបមុខសម្លឹងចំទេ ប៉ុន្តែតាមពិតកាយវិការប្រុសស្រីទាំងពីរ គឺមិនអាចរំលងពីសរសៃចក្ខុបុរសនេះឡើយ។

ពេលនោះគាត់ឃើញនារីមានឋានៈបែរកាយមករកបុរសជាភ្ញៀវកិត្តិយស។ ទោះនាងបិទបាំងភាពរំភើបលើផ្ទៃមុខពីក្រោយផ្ទាំងស្បៃ ប៉ុន្តែពន្លឺភ្នែកនាងបានបញ្ចេញស្នាមញញឹមជំនួស។ នាងគិតពីសម្លឹងបុរសសង្ហាដោយមិននិយាយអ្វីទៀត ប៉ុន្តែបុរសនោះមិននៅស្ងៀមទេ នាយលើកដៃស្ដាំឡើងហើយលាតដៃអាវចេញបង្ហាញនាង ព្រមទាំងនិយាយបន្ត៖

-នាងខាំខ្ញុំជ្រៅម្លឹងៗ ខ្ញុំភ្លេចនាងម៉េចនឹងកើតទៅ?

នារីបង្ហាញភាពរំភើបក្នុងភ្នែក នាងនិយាយតិចៗ៖

-ទីបំផុត អ្នកអត់បានភ្លេចខ្ញុំទេ!

រាមនរិន្ទញញឹមស្រស់ តបទៅនឹងស្នាមញញឹមរបស់ស្រីតូចដែលលាក់ទុកក្នុងស្បៃបិទបាំងផ្ទៃមុខ។ នារីនោះងាកទៅរកលោករ៉ាទូដែលពីមុនមកទល់ពេលនេះឥតបានវាចាសូម្បីមួយម៉ាត់ ដោយនិយាយបង្គាប់៖

-មិត្តចាស់របស់ខ្ញុំមកលេង! យើងត្រូវតែរៀបចំពិធីស្រស់ស្រូបឲ្យធំដុំមួយ មានភ្លេងកំដរ មានទឹកឃ្មុំ និងគ្រាប់អាល់ម៉ុន សាច់ចៀម ពិសេសគឺស្រាស្រូវសាលីរបស់យើង!

បុរសនោះឱនកាយទទួលបទបញ្ជារួចចាកចេញទៅបន្សល់ឲ្យរាមនរិន្ទនូវសំនួរមួយចំនួន ទោះបីអ្នករក្សាស្នាមញញឹមលើផ្ទៃមុខ។

"Meddy នៅសុខៗប្តូរឈ្មោះមកជាអេឡាតើហេតុអីទៅ? ម៉េចក៏នាងទៅជាអ្នកមានឥទ្ធឫទ្ធិមា? កាលរៀនជាមួយគ្នានៅ Australiaនាងមិនមានពាក់ខោអាវបែបនេះហើយបាំងស្បៃមុខអីទេ គ្រប់គ្នាគ្រាន់តែដឹងថានាងមកពីឥណ្ឌូណេស៊ី។ បើនាងជានារីមូស្លីមហេតុអីក៏មានស្រា? តើនាងធ្វើម៉េចអាចដឹងពីដំណើររបស់ពួកយើងមកកាន់កោះស្មៅលឿង?"

នៅខាងក្រោមផ្ទះឈើដែលប្រែទៅជាងងឹតដោយស្រមោលរាត្រីកាល រយៈពេល១០នាទីនៃអវត្តមានកូនប្រុសអ្នកនយោបាយ មិនអាចឲ្យអ្នកណាម្នាក់ដែលរួមដំណើរមករីករាយក្នុងចិត្តទេ។

ក្រុមមនុស្សមកពីស្រុកខ្មែរដែលកំពុងឆ្ងល់ ស្រាប់តែត្រូវបានលោករ៉ាទូចុះមកប្រាប់ថាឲ្យទៅរកសំអាតខ្លួននៅអាគារមួយផ្សេងខាងក្រោយផ្ទះធំ ដើម្បីមកចូលរួមពិធីលៀងសាយភោជនជាកិត្តិយស។

ដោយរេរាមិនទាន់សម្រេចចិត្តយ៉ាងណា ពួកគេក៏ឃើញនាយថៅហ្វាយបង្ហាញខ្លួនមកវិញដោយមាននារីរាងតូចទ្រនាប់កំដរដំណើរ ហើយទោះបីនារីនោះមិនបើកស្បៃបង្ហាញមុខ ប៉ុន្តែមើលពីក្រៅក៏ដឹងថាពួកគេកំពុងសំណេះសំណាលគ្នាដោយរីករាយបំផុតដែរ។